ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
មន្ទីរអប់រំ យុវជន និងកីឡា ខេត្តតាកែវ
វិទ្យាល័យអង្គសង្កែ

# ចូលរួមអបអរទិវាអំណាន

លើប្រធានបទ៖

# «តម្លៃអក្សរសិល្បិ៍នៃរឿងរាមកេរ្តិ៍ក្នុងសង្គមខ្មែរ»

ព.ស.២៥៦៤
គ.ស.២០២១


+ឈ្មោះ ៖ **ទឹម សុខឃួយ** ភេទ ប្រុស

+ថ្ងៃខែឆ្នាំកំណើត ៖ ០៩ មីនា ១៩៨៩

+មុខរបរ ៖ គ្រូបង្រៀន

+អង្គភាពបម្រើការងារ៖ វិទ្យាល័យអង្គសង្កែ(ខេត្តតាកែវ)

+លេខទូរសព្ទ៖ ០៨៦ ៩៦ ៧៧ ២៧ / ០៨៨ ៨៥៥ ៥៣ ៥៣

# មាតិកា


១. សេចក្តីផ្តើម.....២
២. តម្លៃនៃអក្សរសិល្ប៍.....២
២.១. និយមន័យ.....២
២.២. តម្លៃអក្សរសិល្ប៍ក្នុងសង្គម.....៣
៣. អំពីរឿងរាមកេរ្តិ៍.....៤
៣.១. ការបង្ហាញអត្ថបទ.....៤
៣.២. អ្នកនិពន្ធ រៀបរៀង.....៤
៣.៣. កាលកំណត់តែង .....៤
៣.៤. សង្គមបរិយាកាស.....៥
៤. តម្លៃរឿងរាមកេរ្តិ៍ឆ្លុះបញ្ចាំងនូវខេមរនីយកម្ម.....៦
៤.១. តម្លៃលើផ្នែកនយោបាយ.....៦
៤.២. តម្លៃលើផ្នែកសេដ្ឋកិច្ច.....៨
៤.៣. តម្លៃលើផ្នែកសង្គមកិច្ច.....៨
៤.៤. តម្លៃលើផ្នែកវប្បធម៌.....៩
ក. ជំនឿ.....៩
ខ. សាសនា.....១១
គ. ការអប់រំ.....១២
ឃ. សិល្បៈ.....១៣
ង. ភាសា-អក្សរ.....១៤
៤.៥. តម្លៃតាមរយៈលក្ខណៈអក្សរសិល្ប៍.....១៤
៤.៦. តម្លៃតាមរយៈចលនាអក្សរសិល្ប៍.....១៦
៥. សន្និដ្ឋាន.....១៧
ឯកសារពិគ្រោះ.....១៨

## ១.សេចក្ដីផ្ដើម

រាមកេរ្តិ៍ជាស្នាដៃដ៏ល្បីល្បាញ នៅក្នុងអក្សរសិល្ប៍ខ្មែរ ហើយគេចាត់ទុកស្នាដៃដ៏ប្រពៃនេះ ក្នុងរឿងអក្សរសិល្ប៍នៃទ្វីបអាស៊ីទៀតផង។ ម៉្យាងទៀត រឿងរាមកេរ្តិ៍ខ្មែរជារឿងបានទ្រទ្រង់តម្លៃវប្បធម៌អរិយធម៌ជាតិ សិល្បករខ្មែរបានឆ្លាក់ ដំណើររឿងនៅតាមជញ្ជាំងប្រាសាទ។ សម័យក្រោយមករូបចម្លាក់ទាំងនោះបានប្រែក្លាយទៅជាក្បាច់របាំតន្ត្រីយ៉ាងរស់រវើកដែលភ្ញៀវជាតិអន្តរជាតិទទួលនិងឱ្យតម្លៃយ៉ាងខ្ពស់បំផុត។ រឿងរាមកេរ្តិ៍ខ្មែរត្រូវបានគេធ្វើការកែច្នៃពីរឿងរាមាយណៈឥណ្ឌាមកជារបស់ខ្មែរ ហើយស្របតាមចិត្តគំនិតជាតិយើង ដែលអាចឱ្យខ្មែរយើងទទួលយកបាន និងដឹងឮគ្រប់គ្នាទូទាំងប្រទេស ព្រមទាំងចាត់ទុករឿងនេះទៀតសោតជាអក្សរសិល្ប៍ជាតិ ហើយស្ថិតនៅក្នុងព្រលឹងជាតិខ្មែរមិនចេះរីងស្ងួត។

រឿងរាមកេរ្តិ៍ មានន័យថាជារឿង ឬសេចក្ដីសរសើរចេស្ដាល្បីល្បាញរបស់ព្រះរាម។ រាមកេរ្តិ៍សឹងតែជាស្នាបត្យកម្មអក្សរសាស្ត្រខ្មែរ ដែលយើងបានដាក់ក្នុងកម្មវិធីសិក្សាអក្សរសាស្ត្រនៅមធ្យមសិក្សា និងឧត្តមសិក្សានៅឆ្នាំ១៩៥៨-១៩៧៥។ ខ្មែរស្គាល់រឿងរាមកេរ្តិ៍ទូទាំងប្រទេស តែការយល់ពីដឹងពីរឿងនេះមានបញ្ហាច្រើនជាឧបសគ្គ ព្រោះអត្ថបទរឿងពិបាកដោយមានពាក្យពេចន៍ដែលយើងលែងប្រើនៅបច្ចុប្បន្នភាព។ ខ្មែរបានសិក្សាពីរឿងនេះច្រើន តែសេចក្ដីអធិប្បាយទូលំទូលាយពីខ្លឹមសារស៊ីជម្រៅឡើយ។ រឿងរាមកេរ្តិ៍ គឺបានតាក់តែងឡើងជាកាព្យ មានឃ្លាឃ្លោងសម្រាប់ពោលស្មូត្រឱ្យមហាជនស្ដាប់ ឬសម្ដែងជាមហោស្រពជាដើម។

លក្ខណៈពិសេសក្នុងរឿងរាមកេរ្តិ៍ខ្មែរ គឺលក្ខណៈពុទ្ធនិយមមានពាសពេញរឿងទាំងផ្នែកទស្សនៈ ទាំងផ្នែកពាក្យពេចន៍ជាច្រើនដូចជាទស្សនៈពីជាតិ ជរា ព្យាធិ មរណៈ និងនិព្វានជាដើម។ ក្រៅពីនេះរឿងរាមកេរ្តិ៍បានផ្សារភ្ជាប់នឹងជីវិតខ្មែររាល់ថ្ងៃ ជនជាតិខ្មែរយើងបានបញ្ជ្រាបរឿងរាមកេរ្តិ៍ ទៅក្នុងសិល្បៈគំនូរ ចម្លាក់តាមវត្តនិងប្រាសាទនានា របាំ ក្នុងជំនឿ ក្នុងក្បួនទាយ ក្នុងឈ្មោះក្បាច់គុន ឈ្មោះរុក្ខជាតិ ក្នុងសញ្ញាសម្គាល់ស្ថាប័នជាតិនិងអង្គការ ព្រមទាំងក្នុងព្រះរាជពិធីរបស់ព្រះមហាក្សត្រផងដែរ។ ទាំងនេះសបញ្ជាក់ឱ្យឃើញថា រឿងរាមកេរ្តិ៍បានជ្រាបចូលយ៉ាងជ្រៅទៅក្នុងជីវិតរបស់ប្រជាជនខ្មែរ តាំងពីបុរាណរហូតដល់បច្ចុប្បន្ន។ រឿងរាមកេរ្តិ៍ខ្មែរមានប្រជាប្រិយភាពក្នុងសង្គម ដែលមានអ្នកសិក្សាអក្សរសាស្ត្រមួយចំនួនចាត់ទុកជា«ប្រាសាទអក្សរសាស្ត្រ»[1] មួយដ៏ធំក្នុងវប្បធម៌ អរិយធម៌ខ្មែរយើង។

## ២. តម្លៃនៃអក្សរសិល្ប៍

### ២.១. និយមន័យ

ការសិក្សាពីនិយមន័យនៃ«អក្សរសិល្ប៍» គេសង្កេតឃើញទស្សនៈប្លែកៗគ្នាដូចជា៖

- តាមវាក្យសព្ទ «អក្សរសិល្ប៍ < អក្សរ+សិល្ប៍»
  - អក្សរ គឺស្នាមគំនូសផ្សេងៗ ដែលយើងប្រើប្រាស់នៅក្នុងការកត់ត្រាសូរភាសា។
  - សិល្ប៍ គឺសំដៅដល់រូបារម្មណ៍ វិធី ឬបែបបទ ដែលប្រកបដោយសិល្បៈ[2]។

ដូចនេះ អក្សរសិល្ប៍ គឺជាស្នាមគំនូស ឬជាកម្រងអត្ថបទពាក្យរាយ ឬពាក្យកាព្យទាំងឡាយណា ដែល

[1] យីង ហុកឌី, ទិដ្ឋភាពទូទៅនៃអក្សរសាស្ត្រខ្មែរ,២០០៣

[2] សម្ដេចសង្ឃរាជជួន ណាត វចនានុក្រមខ្មែរ ១៩៦៧

កើតពីសមត្ថភាពរបស់អ្នកនិពន្ធ បង្កើតបានជាសាច់រឿងដោយបូកផ្សំជាមួយនឹងបទពិសោធប្រកបដោយរូបារម្មណ៍។

- ទស្សនៈលោក កេង វ៉ាន់សាក់ លើកឡើងថា «អក្សរសិល្ប៍ គឺជាវិទ្យាស្បង់ មួយដែលបានលើកយកបញ្ហាមនុស្សមកចោទ និងដោះស្រាយទៅតាមសិល្បវិធី និងទៅតាមសង្គមនីមួយៗ»[3]។
- តាមមទស្សនៈរបស់លោក ម៉ាក់ស៊ីមគ័រគី(Maxime Gorky) ជនជាតិរុស្សី លោកបានអះអាងថា «អក្សរសិល្ប៍គឺជាមនុស្សវិជ្ជា»។
- ទស្សនៈរបស់លោកប៊ីយេនសិនស្គី ជនជាតិរុស្សីបានយល់ថា «អក្សរសិល្ប៍ជាកម្រងឯកសារនៃជីវិត»។
- តាមទស្សនៈលោកសង់ ប៉ូលសាត្រ ជនជាតិបារាំងបាននិយាយថា «អក្សរសិល្ប៍គឺជាអធិប្បាយផ្សាយចិត្តគំនិតរបស់អ្នកនិពន្ធ»។

## ២.២. តម្លៃអក្សរសិល្ប៍ក្នុងសង្គម

តម្លៃនៃអក្សរសិល្ប៍ក្នុងសង្គមរមែងផ្សារភ្ជាប់និងវប្បធម៌ អរិយធម៌។ អក្សរសិល្ប៍គឺជាមែកធាងដ៏សំខាន់នៃវប្បធម៌។ ស្នាដៃអក្សរសិល្ប៍នីមួយៗគឺជាការកំណត់នូវអត្តសញ្ញាណរបស់ជាតិសាសន៍នីមួយៗ។ តាមរយៈអក្សរសិល្ប៍គេអាចវាយតម្លៃពីប្រវត្តិ និងឥទ្ធិពលរបស់សង្គមជាតិទាំងឡាយបាន។ ជាធម្មតាប្រទេសជឿនលឿនក៏តែងតែមានប្រវត្តិជាប់ទាក់ទងទៅនឹងអក្សរសិល្ប៍ ដែលមានការរីកចម្រើនពីអតីតកាលដែរ។

អក្សរសិល្ប៍គឺជាកញ្ចក់ឆ្លុះបញ្ចាំងពីសង្គមមនុស្ស។ អក្សរសិល្ប៍មានតម្លៃ និងសារៈសំខាន់ណាស់នៅក្នុងជីវភាពនៃការរស់នៅប្រចាំថ្ងៃ។ ការឈ្វេងយល់ឱ្យបានច្បាស់លាស់ពីអក្សរសិល្ប៍ គឺជាការផ្តល់តម្លៃដល់ខ្លួនឯងផង និងដល់សង្គមផង។ អក្សរសិល្ប៍មិនមែនផ្តោតតែទៅលើសំណេរជាអក្សរនៅលើក្រដាសនោះទេ អក្សរសិល្ប៍រាប់បញ្ចូលទាំងសិល្បៈច្រើនទម្រង់ច្រើនបែបយ៉ាង និងមានលក្ខណៈវិនិច្ឆ័យខុសៗគ្នា[4]។

នៅពេលដែលវិទ្យាសាស្រ្ត និងបច្ចេកវិទ្យាកាន់តែទំនើប និងរីកចម្រើន តម្លៃនៃអក្សរសិល្ប៍បានធ្លាក់ចុះដោយសារតែអ្នកសិក្សាក្តី យុវជនក្តីពុំទាន់បានមើលឃើញភ្លាមៗអំពីសារៈប្រយោជន៍នៃការសិក្សាឈ្វេងយល់ពីអក្សរសិល្ប៍នោះទេ។ ដូច្នេះហើយទើបធ្វើឱ្យមានការព្រួយបារម្ភថានាពេលអនាគតសង្គមខ្មែរនឹងមិនមានអក្សរសិល្ប៍ ដែលមានតម្លៃដើម្បីបន្សល់ទុកជាស្នាដៃជាតិនោះទេ។ ដើម្បីជំរុញឱ្យអក្សរសិល្ប៍មានតម្លៃក្នុងសង្គម ទៅបាន យើងត្រូវបង្ហាញឱ្យស្គាល់ពីតម្លៃនៃអក្សរសិល្ប៍របស់ជាតិ លក្ខណៈពិសេសនៃអក្សរសិល្ប៍ជាតិ។

អក្សរសិល្ប៍នីមួយៗមានលក្ខណៈពិសេសរបស់ខ្លួន ដើម្បីមានតម្លៃក្នុងសង្គមដូចជាៈ លក្ខណៈជាតិនិយម លក្ខណៈតថនិយម។ លក្ខណៈជាតិនិយម គឺបានដល់ស្នាដៃទាំងឡាយដែលឆ្លុះបញ្ចាំង និងរក្សាបានយ៉ាងល្អនូវអ្វីៗដែលជារបស់ជាតិផ្ទាល់ ហើយបើមានការជះឥទ្ធិពលពីបរទេស ក៏ខ្មែរបានច្នៃកាឡៃឱ្យទៅជាលក្ខណៈជាតិផ្ទាល់ ដោយពុំបានរក្សាលក្ខណៈបរទេសនិយមឡើយ។ លក្ខណៈតថនិយម គឺបានដល់ស្នាដៃដែលឆ្លុះបញ្ចាំងពីភាពពិតៗដែលមានក្នុងជីវិតពិត ឬសង្គមជាក់ស្តែងបានល្អ ឥតកែកាឡៃពីការពិត។ ខ្មែរមានចរិតពិសេសមួយគឺ ពុំសូវមានចំណូលចិត្តនូវអ្វីដែលខ្ពង់ខ្ពស់ហួសពីនិស្ស័យរបស់មនុស្សជាតិ ហើយបើសិនជាអស្ចារ្យប្លែកវិញ គឺអស្ចារ្យបម្រើឱ្យការពិត។

---

[3] ញៅ សាមី, មូលដ្ឋានទ្រឹស្តីអក្សរសិល្ប៍,១៩៨៧

[4] លោកសាស្ត្រាចារ្យ ហ៊ីង យ៉ាន ព្រឹទ្ធបុរសរងនៃពុទ្ធិកៈសាកលវិទ្យាល័យព្រះសីហនុរាជ។

## ៣.អំពីរឿងរាមកេរ្តិ៍

### ៣.១. ការបង្ហាញអត្ថបទ

- **ប្រភព**: រាមកេរ្តិ៍ត្រូវបានអ្នកសិក្សាមួយចំនួនចោទថាចម្លងចេញពីរាមាយណៈឥណ្ឌា ព្រោះនៅឥណ្ឌា ក៏មានរឿងស្រដៀងគ្នានេះដែរ គឺមានរហូតដល់បីរឿងឯណោះដូចជា ៖
    - **រឿងរាមាយណៈ** ៖ជាស្នាដៃលោក**វាល្មិកិ** និពន្ធនៅស.វទី៣មុនគ.ស។ ការសរសេររឿងនេះក្នុងបំណង រំឭកពីសង្គ្រាមសាសនារវាងពួកអារ្យ៉ន ដែលជាអ្នកកាន់សាសនាហិណ្ឌូនៅឥណ្ឌា និងពួកលង្កាជាអ្នកកាន់ព្រះពុទ្ធសាសនា។
    - **រឿងអធ្យាត្មរាមាយណៈ** ៖ និពន្ធឡើងដើម្បីទាញមនុស្សឱ្យកាន់សាសនាព្រាហ្មណ៍ ដែលមានព្រះរាមជាអវតារទី៧ជាទីសក្ការៈ។ ពួកគេយល់ថា ដំណើររឿងរបស់វាល្មិកិមានពេលខ្លះព្រះរាមបានប្រព្រឹត្តខុសធ្វើឱ្យខូចឈ្មោះអាទិទេព។ ដូច្នេះគេយល់ថាត្រូវតែរៀបចំរឿងនេះឡើងវិញ គឺឱ្យតួអង្គព្រះរាមមានជ័យជម្នះតាំងពីដើមរហូតដល់ចប់។
    - **រឿងរាមចរិតមានស** ៖ ស្នាដៃលោកទុលស៊ីដាស។ និពន្ធរឿងនេះក្នុងស.វ.ទី១៦ ក្នុងបំណងទាញមនុស្សកុំឱ្យជឿលើអាទិទេពខ្លាំងពេក។ លោកយល់ថា រឿងមុនៗល្អសម្រាប់ផ្សាយសាសនាមែនតែការលើកតម្លៃអាទិទេពហួសហេតុពេកនាំឱ្យបាត់បង់តម្លៃមនុស្ស។
- **ប្រភេទ** ៖ យោងលើសាច់រឿង គឺមានលក្ខណៈវែងអន្លាយពោរពេញទៅដោយសង្គ្រាមតស៊ូប្រយុទ្ធគ្នា និងអត្ថរូបនៃរឿងគឺសរសេរជាកំណាព្យ ហើយចែកជាវគ្គខ្លីៗជាឈុត និងឆាកដាច់ៗទៅតាមដំណើររឿងសម្រាប់សម្តែង ដោយមានភ្លេងប្រគំផងនោះ គេអាចសន្និដ្ឋានថា រឿងរាមកេរ្តិ៍គឺស្ថិតក្នុងប្រភេទ «*នាដ្យកថាប្រកបទៅដោយវីរលក្ខណៈ*»។
- **ចលនា** ៖ ការផ្តើមរឿងកវីបានបង្ហាញពិធីបូជាយញ្ញតាមព្រហ្មញ្ញសាសនា គឺហោមពិធីរបស់ឥសីពិស្វាមិត្រ។ ដូច្នេះ គេអាចសន្និដ្ឋានថា រឿងរាមកេរ្តិ៍ ស្ថិតក្នុង**ចលនាព្រាហ្មណ៍និយម**។

### ៣.២. អ្នកនិពន្ធ រៀបរៀង

- **ឈ្មោះនិពន្ធ** : អ្នកអង្គម្ចាស់វឌ្ឍឆាយាវង្ស (ឯកសារដែលបានដាក់បញ្ចូលកម្មវិធីសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡា)។

### ៣.៣. កាលកំណត់តែង

**៣.១.១.** អ្នកស្រាវជ្រាវបានបង្ហាញកាលបរិច្ឆេទផ្សេងៗគ្នា ទៅតាមហេតុផលរៀងខ្លួនដូចជា៖

- <u>**យោបល់ទី១**</u>: បណ្ឌិត **មីសែលត្រាណេ**[5] តាមរយៈសៀវភៅ «ការសិក្សារឿងរាមកេរ្តិ៍» បានអះអាងថា សាច់រឿងបែបខ្មែរត្រូវគេលើកយកមកសិក្សាដើម្បីបង្ហាញពីជម្លោះរវាងសាសនាព្រាហ្មណ៍ និងសាសនាព្រះពុទ្ធមហាយានក្នុងរាជ្យព្រះបាទឥន្ទ្រវរ្ម័នទី២ និងជ័យវរ្ម័នទី៨ នាស.វ.ទី១៣ទើបបានជាមានការតាក់តែងបង្ហាប់ តួអង្គព្រះរាម។
- <u>**យោបល់ទី២**</u>: លោក**ញ៉ុកថែម**[6]មិនបានបញ្ជាក់នៅក្នុងតារាងប្រវត្តិសាស្ត្រអក្សរសិល្ប៍ខ្មែរ៖

[5] ការសិក្សារឿងរាមកេរ្តិ៍ មីសែល ត្រាណេ ១៩៩៥ អារម្ភកថាទំព័រទី១ បន្ទាត់ទី៨ដល់ទី១៣

[6] ការសិក្សារឿងរាមកេរ្តិ៍ មីសែល ត្រាណេ ១៩៩៥ ទំព័រទី៣

- ខ្សែទី១-១០ ប្រហែលរៀបរៀងនៅស.វ.ទី១៧-១៨ រវាងរជ្ជកាលព្រះបាទជ័យជេដ្ឋាទី៤ មកទល់នឹងព្រះអង្គអេង ហើយតែងដោយអ្នកនិពន្ធម្នាក់។
- ខ្សែទី៧៥-៨០ ប្រហែលតែងក្នុងរជ្ជកាលរបស់ព្រះពញាអង្គអេងមកទល់អង្គឌួង តែងដោយអ្នកនិពន្ធម្នាក់ផ្សេងទៀត។

➢ **<u>យោបល់ទី៣</u>**: អ្នកស្រី **ពៅ សាវរស**[7] បានចែករឿងរាមកេរ្តិ៍ជាពីរជំពូកគឺ៖

- ផ្នែកទី១៖ ត្រូវនឹងសៀវភៅពុទ្ធសាសនបណ្ឌិត្យភាគ១-១០ មានទាំងអស់ ៥០៣៤ វគ្គកំណាព្យតែងឡើងរវាងស.វ.ទី១៦-១៧។
- ផ្នែកទី២៖ ត្រូវនឹងសៀវភៅពុទ្ធសាសនបណ្ឌិត្យភាគ៧៥-៨០ មានទាំងអស់ ១៧៧៤វគ្គកំណាព្យតែងឡើងរវាងពាក់កណ្តាលស.វ.ទី១៨។

➢ **<u>យោបល់ទី៤</u>**៖ លោក**សរ សារុន** បានវិភាគទៅលើកាលបរិច្ឆេទរឿងដោយ យោងទៅលើវិធីបីយ៉ាងគឺ៖

- **វិធីទី១**៖ ប្រៀបធៀបពាក្យសម្តីក្នុងរឿងរាមកេរ្តិ៍ខ្មែរទៅនឹងសិលាចារឹកនៅសម័យណាមួយ។
- **វិធីទី២**៖ ប្រៀបធៀបដំណើររឿងរាមកេរ្តិ៍ទៅនឹងចម្លាក់នៅតាមជញ្ជាំងប្រាសាទ។ គេបានរកឃើញមានប្រាសាទបួន ដែលមានឆ្លាក់ដំណើររឿងទាក់ទងនឹងរឿងរាមកេរ្តិ៍ និងរឿងរាមាយណៈដូចជា៖ កោះកេរ (ដើមស.វ.ទី១០)[8] បន្ទាយស្រី (ពាក់កណ្តាល ស.វ.ទី១០) បាពួន (ដើមស.វ.ទី១១) អង្គរវត្ត (ដើមស.វ.ទី១២)
- **វិធីទី៣**៖ ប្រៀបធៀបបរិយាកាសរឿងទៅនឹងសង្គមបរិយាកាសក្នុងសម័យណាមួយ។ រឿងរាមកេរ្តិ៍កើតឡើងនៅពេលមានទំនាស់សាសនាព្រាហ្មណ៍ និងព្រះពុទ្ធសាសនា។ ដូចនេះរឿងរាមកេរ្តិ៍ស្ថិតក្នុងបរិយាកាសវិស្ណុនិយម ដោយអ្នកនិពន្ធពុំហ៊ានចេញមុខប្រឆាំងនឹងព្រះរាមដោយវិធីត្រង់ទេ។

ការបញ្ចូលដំណើររឿងដែលទាក់ទងនឹងសង្គមបរិយាកាសខ្មែរបែបនេះ បានធ្វើឱ្យរឿងរាមកេរ្តិ៍ខ្មែរមានតម្លៃពិសេសរបស់ខ្មែរ។ ដូច្នេះតាមរយៈបរិយាកាសនៃទំនាស់សាសនា ដូចយើងបានអធិប្បាយរួចមកហើយ ធ្វើឱ្យយើងសន្និដ្ឋានថារឿងរាមកេរ្តិ៍តែងឡើងប្រហែល**ចុងស.វ.ទី១២ និងដើមស.វ.ទី១៣**។

**៣.១.២. ថ្ងៃ ខែ ឆ្នាំ នៃការបោះពុម្ព** : ព.ស.២៥៣៩ ដោយពុទ្ធសាសនបណ្ឌិត្យ។

## ៣.៤. សង្គមបរិយាកាស

➢ **កាលប្បវត្តិ** ៖ រឿងរាមកេរ្តិ៍ គឺជាការប្រែសម្រួលនៃរឿងរាមាយណៈ។ ពាក្យពេចន៍ ដែលបានប្រើក្នុងរឿងនេះ ជាភាសាបាលីសំស្ក្រឹត។ អ្នកដែលនាំរឿងនេះទៅនិយាយផ្សាយក៏ពោលបន្ថែមបន្ថយ ឬបំពេញតាមអធ្យាស្រ័យរបស់ខ្លួន ដើម្បីឱ្យបានពីរោះដល់អ្នកស្តាប់។ ហេតុនេះហើយបានជាភាសាសំស្ក្រឹតដែលនិទានតៗគ្នាពីមួយទៅមួយ បានក្លាយជាអក្សរសាស្ត្រសម្រាប់សាសនា។

➢ **ព្រឹត្តិការណ៍សំខាន់**៖ រឿងរាមកេរ្តិ៍ជាស្នាដៃអក្សរសិល្ប៍ តំណាងឱ្យសង្គមពេលនោះ កំពុងមានទំនាស់វិបត្តិសាសនារវាងពុទ្ធសាសនានិងព្រាហ្មណ៍សាសនារវាងនិកាយ វិស្ណុនិងសិវៈ។

[7] សិក្សាសង្ខេបរឿងរាមកេរ្តិ៍ សរ សារុន ទំព័រទី១ បន្ទាត់ទី១៤

[8] សិក្សាអត្ថបទទុំទាវ រាមកេរ្តិ៍ កម្មវិធីសិក្សាអក្សរសិល្ប៍ថ្នាក់ទី១០ ឆ្នាំ១៩៨៨

## ៤.តម្លៃរឿងរាមកេរ្តិ៍ ឆ្លុះបញ្ចាំងនូវខេមរនិយកម្ម

តាមរយៈរឿងរាមកេរ្តិ៍ បានឆ្លុះបញ្ចាំងពីលក្ខណៈជាតិនិយមនិងតថនិយម ក្នុងសង្គមយ៉ាងច្រើនដូចជា៖ អ្នកដឹកនាំគ្រប់រូបកុំឈ្លក់វង្វេងនឹងសម្រស់ស្រី ឱ្យមនុស្សគ្រប់រូបមានស្មារតីរឹងប៉ឹង ចំពោះហេតុការណ៍ដែលកើតឡើងចំពោះមុខពិសេស គឺដោះស្រាយបញ្ហាដោយសន្តិវិធី អប់រំមនុស្សគ្រប់រូប គ្រប់សាសន៍ឱ្យគោរពនិងរស់នៅជាមួយគ្នាដោយសន្តិភាព។ លើសពីនេះ ក្នុងសង្គមបរិយាកាសដែលព្រហ្មញ្ញសាសនាកំពុងគ្របដណ្តប់លើសង្គមយ៉ាងជិតឈឹងនោះ ស្រាប់តែគេបានបង្ហាញចេញតាមរយៈសាច់រឿងនូវការបញ្ចុះទេវភាព ហើយបែរជាលើកតម្លៃមនុស្ស ដែលដោះស្រាយបញ្ហាដោយប្រើសមត្ថភាព គំនិត ប្រាជ្ញា កលល្បិច រៀងៗខ្លួនដើម្បីសម្រេច បើបញ្ហាណាធូរស្រាលដោះស្រាយបាន ប្រសិនជាធ្ងន់ធ្ងរក៏ត្រូវបរាជ័យដូចករណីព្រះរាមជាដើម។ ក្រៅពីនេះគឺបង្ហាញនូវលក្ខណៈចក្រពត្តិផ្តាច់ការរបស់ពួកជនមួយចំនួន ដែលបានធ្វើគ្រប់យ៉ាង ដើម្បីបម្រើមហិច្ឆតារបស់ខ្លួន បង្ហាញពីចរិត ស្នេហាជាតិ និងក្បត់ជាតិរបស់ជនមួយចំនួននោះផងដែរ។ ជាតថនិយមអ្នកដឹកនាំត្រូវចេះគិតដល់ប្រជារាស្ត្រគិតប្រយោជន៍រួមជាធំ មិនអត្តនោម័តមិនព្រមស្តាប់យោបល់អ្នកក្រោមបង្គាប់នោះឡើយ។ ចំណុចពិសេសមួយទៀតគឺផ្តោតលើការគោរពទំនៀមទម្លាប់ គោរពពាក្យសត្យ ពាក្យសច្ចៈ ឬពាក្យសន្យារួចហើយ។ ទាំងអស់នេះសុទ្ធតែជាការបង្ហាញនូវតម្លៃនៃអក្សរសិល្ប៍រឿងរាមកេរ្តិ៍ដោយផ្តោតលើលក្ខណៈជាតិនិយមនិងលក្ខណៈតថនិយម។

រឿងរាមកេរ្តិ៍ មានការវិវត្តដក់ជាប់ក្នុងសតិអារម្មណ៍ខ្មែរ ហើយក៏ជាសមាសភាគមួយនៃវប្បធម៌ខ្មែរ។ ខ្មែរអាចបង្ហាញរឿងរាមកេរ្តិ៍តាមរូបភាព៖រូបចម្លាក់នៅផ្ទាំងថ្មប្រាង្គប្រាសាទនានានៅអង្គរ, អក្សរសិល្ប៍, រឿងនិទានដោយមាត់ទទេ, កែក្រឡៃយកទៅសម្តែងជាល្ខោន(ល្ខោនព្រះរាជទ្រព្យ), គូរហើយផាត់ពណ៌(ពិសេសគំនូរនៅលើថែវវិហារព្រះកែវ), ល្ខោនស្បែកធំ, សរសេរជាក្បួនទស្សន៍ទាយរបស់ហោរាសាស្ត្រ, គំនូរតួអក្សរខ្មែរធៀបនឹងរឿងរាមកេរ្តិ៍ជាដើម។ រឿងរាមកេរ្តិ៍ខ្មែរបានបញ្ជាក់នូវសភាវៈរបស់មនុស្សស្ថិតនៅលើផែនដី ដែលជួបនឹងបញ្ហាជម្លោះទាស់ទែង តណ្ហាមិនចេះស្កប់ស្កល់ ការបំបរបង់។ល។

ជារួមតម្លៃនៃអក្សរសិល្ប៍រឿងរាមកេរ្តិ៍ស្តែងឡើងក្រោមរូបភាពជាច្រើន ដែលបន្តមកដល់បច្ចុប្បន្ននៅតែជិតដានក្នុងផ្នត់គំនិតខ្មែរ ហើយមានតម្លៃជានិរន្តរ៍។ រឿងរាមកេរ្តិ៍នៅតែមានតម្លៃក្នុងសង្គមខ្មែរជានិច្ច ពិសេសបើយើងសិក្សាលើបញ្ហាសង្គម តាមរយៈផ្នែកធំៗ វិស័យធំៗរបស់ជាតិយើងនឹងឆ្លុះតាមរយៈ នយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។

### ៤.១. តម្លៃលើផ្នែកនយោបាយ

ដោយផ្អែកតាមដំណើររឿងរាមកេរ្តិ៍បានបង្ហាញថា ការគ្រប់គ្រងសង្គមនាសម័យនោះប្រព្រឹត្តទៅដោយព្រះរាជា។ ការគ្រងរាជ្យសម្បត្តិដោយផ្អែកទៅលើរាជក្សត្រ ឬប្រពៃណីក្សត្រ ដែលតម្រូវឱ្យបុត្រច្បងត្រូវឡើងគ្រងរាជ្យមុនបុត្រប្អូន។ ម្យ៉ាងទៀត ចំពោះកិច្ចការពារឬការធ្វើសង្គ្រាមប្រឈមមុខនឹងសត្រូវពិតជាមានយុទ្ធវិធីខ្ពស់មានការ គ្រប់គងកងទ័ពបានល្អ និងមានល្បិចកលដើម្បីយកឈ្នះលើខ្មាំងសត្រូវ។

- **នយោបាយក្នុងប្រទេស** ៖ ការគ្រប់គ្រងតាមបែបរាជានិយម ដែលមានព្រះមហាក្សត្រជាអ្នកគ្រប់គ្រង ហើយការសោយរាជ្យមានលក្ខណៈបន្តវេន ឬប្បវេណី ដែលបុត្រច្បងមានសិទ្ធិក្នុងការបន្តវេនពីព្រះបិតា។ នៅនគរព្វយុធ្យា មានព្រះបាទទសរថជាអ្នកសោយរាជ្យ និងព្រះរាមជាអ្នកត្រូវអ្នកបន្តវេន។ ក្រៅពីនេះនៅលង្កាបុរីគឺមានច្បាប់ប្រចាំនគរដូចជាគេមិនសម្លាប់មនុស្សដែលគ្មានទោសពៃរ៍ឡើយ។

- **នយោបាយក្រៅប្រទេស** ៖ នយោបាយចក្រពត្តិនិយម ដែលវាតទីលើប្រទេសតូចតាចដើម្បីគ្រប់គ្រង ឬធ្វើអាណានិគម និងដើម្បីទាញប្រយោជន៍។ ព្រះរាមបានធ្វើនយោបាយបែបនេះជាមួយនឹងនគរស្វាខាស់ខិនបុរី ដែលបានចូលរួមសម្លាប់ពាលី ហើយលើកសុគ្រីពឱ្យធ្វើជាស្តេច ដោយភ្ជាប់គោលបំណងប្រាថ្នាជាថ្នូរនឹងឱ្យសុគ្រីពកេណ្ឌទ័ពទៅជួយខ្លួននៅនគរលង្កា។ លើសពីនេះទៅទៀតព្រះរាម បានគំរាមកំហែង ស្តេចមហាទ្វីប ឈ្មោះមហាជម្ពូទៀតផង។ ពោលគឺប្រទេសធំ ឬមានអំណាចជាអ្នកមានសិទ្ធិក្នុងការកំណត់លើប្រទេសតូចតាច។
- **យុទ្ធសាស្ត្រក្នុងការធ្វើសឹកសង្គ្រាម**[9]៖
  - **យុទ្ធវិធីរបស់ព្រះរាម៖**
    - ✓ **បំបែកបំបាក់ដើម្បីគ្រប់គ្រង៖** ញុះញង់បងប្អូនពាលី សុគ្រីពឱ្យមានទំនាស់នឹងគ្នាកាន់តែខ្លាំង រួចលួចសម្លាប់ពាលី ប្លន់យកអំណាចឱ្យសុគ្រីពក្នុងការកេណ្ឌទ័ពថ្វាយព្រះអង្គ។ (រាមកេរ្តិ៍ ខ្សែទី៥ ទំ.២៩)
    - ✓ **ចងសម្ព័ន្ធមិត្ត៖** ព្រះរាមបានចាត់ពលសេនាជំនិត ពោលគឺហនុមាន និងអង្គទដើម្បីទៅចងសម្ព័ន្ធមិត្តជាមួយស្តេចស្វាក្រឡេកឆេះគឺមហាជម្ពូ។ (រាមកេរ្តិ៍ខ្សែទី៧ ទំ.១០)
    - ✓ **នយោបាយកុហកបោកប្រាស់៖** ខ្ចីអាវព្រះនារាយណ៍មកពាក់បន្លំភ្នែកមហាជម្ពូ ដើម្បីឱ្យមេទ័ពនេះរណបទ្រង់និងយល់ព្រមជួយកងទ័ពក្នុងការធ្វើសង្គ្រាម។ (រាមកេរ្តិ៍ខ្សែទី៧ ទំ.២០)
    - ✓ **គាបសង្កត់អ្នកទន់ខ្សោយ៖** គំរាមកំហែងនាងមណីមេខលាឱ្យសង់ស្ពានទៅលង្កា(រាមកេរ្តិ៍ខ្សែទី៧ ទំ.៤៨) និងគំរាមកំហែងទេវតាឱ្យជួយពេលប្រយុទ្ធនឹងឥន្ទ្រជិត(ខ្សែទី៩ ទំ.៤៩)។
    - ✓ **ប្រើចិត្តសាស្ត្រ៖** ទិញទឹកចិត្តអ្នកក្រោមបង្គាប់ដើម្បីឱ្យបម្រើព្រះអង្គដូចជាបញ្ចុះបញ្ចូល បញ្ចើចបញ្ចើ ដោយផ្តល់រង្វាន់ឱ្យហនុមានផ្តល់បុណ្យស័ក្តិដល់ពិភេក ដែលបានចុះចូលខាងខ្លួន ហើយអន្ទងលួងលោមកុម្ភកាណ៌ឱ្យស្ម័គ្រចិត្តនៅខាងខ្លួនទៀត។(រាមកេរ្តិ៍ខ្សែទី៧ ទំ.៥)
  - **យុទ្ធវិធីរបស់ក្រុងរាពណ៍៖**
    - ✓ **វិធីផ្តាច់ស្បៀង៖** ឱ្យយក្សឈ្មោះរុក្ខសេនទៅយាមការពារព្រៃកុំឱ្យទ័ពស្វាបេះផ្លែឈើស៊ីបាន។ (រាមកេរ្តិ៍ខ្សែទី៨ ទំ.១៥)
    - ✓ **សង្គ្រាមចិត្តសាស្ត្រ៖** យកនាងសីតាហោះឡើងទៅលើអាកាស ដើម្បីបញ្ឈឺចិត្តព្រះរាមឱ្យបាត់បង់ប្រសិទ្ធភាពក្នុងការបញ្ជាសឹកសង្គ្រាម។ លើសពីនេះឱ្យកូនស្រីរបស់ពិភេកប្រែកាឡាជានាងសីតាស្លាប់ដើម្បីបំភ័ន្តភ្នែកព្រះរាម។(រាមកេរ្តិ៍ខ្សែទី៨ ទំ.១៩)
    - ✓ **យុទ្ធសាស្ត្រប្រើថ្នាំពិស៖** ស្លថ្នាំពិសដើម្បីសម្លាប់ទ័ពស្វា«ស្រេចស្លថ្នាំពិសដ៏ប្រាកដ ក៏នៅសាចពលស័ត សហស្សពានរឱ្យលាញ»។[10] (រាមកេរ្តិ៍ខ្សែទី១០ ទំ.២)
    - ✓ **ប្រើអំណាចផ្តាច់ការ៖** ប្រើអាជ្ញានិយមមកលើកងទ័ព មានះពុំព្រមស្តាប់តាមយោបល់អ្នកដទៃហើយបង្ខិតបង្ខំឱ្យគេគោរពតាមបញ្ជាខ្លួន។

---

[9] សិក្សាអត្ថបទអក្សរសិល្ប៍, នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ឆ្នាំ២០១៩

[10] រាមកេរ្តិ៍ខ្សែទី១០ ទំព័រទី១-២ ពុទ្ធសាសនបណ្ឌិត្យ បោះពុម្ពលើកទី២ ឆ្នាំ១៩៥៩

### ៤.២. តម្លៃលើផ្នែកសេដ្ឋកិច្ច

- **សេដ្ឋកិច្ច កសិកម្ម ៖** ស្ថានភាពអំណោយផល ធ្វើឱ្យសម្បូរនូវផ្លែឈើសម្បូរបែប ដែលបញ្ជាក់តាមរយៈរុក្ខសេនទទួលបញ្ជាឱ្យមកការពារផ្លែឈើ។ម្យ៉ាងវិញទៀតតាមរយៈសកម្មភាពរបស់ព្រះចៅក្រុងមិថិលាបានធ្វើពិធីច្រត់ព្រះនង្គ័ល ដែលជានិមិត្តរូបនៃកសិកម្ម ការដាំដុះដាំណាំនានា។
- **ផលិតកម្ម សិប្បកម្ម ៖** បង្ហាញពីការធ្វើនង្គ័ល តាមរយៈព្រះបាទជនក ការធ្វើធ្នូតាមរយៈតួអង្គព្រះរាមឯការធ្វើកម្រាលព្រំបង្ហាញតាមរយៈតួអង្គនាងសីតាចង់បានស្បែកប្រើសមាសជាដើម។
- **គមនាគមន៍៖** គមនាគមន៍ត្រូវបានបែងចែកជា៣ប្រភេទគឺ៖
  - **ផ្លូវគោក** : បង្ហាញតាមរយៈតួអង្គព្រះរាម សីតា ព្រះលក្សណ៍បានធ្វើដំណើរដោយថ្មើរជើង ពីព្រះនគរទៅភ្នំចិត្រកូដ ទៅភ្នំទណ្ឌកាណ៌។
  - **ផ្លូវអាកាស** : បង្ហាញពីការហោះហើររបស់ហនុមានទៅក្រុងលង្កាដើម្បីជួបនាងសីតា ហោះទៅរកថ្នាំ ហោះលើកមហាជម្ពូទាំងគ្រែ។ល។
  - **ផ្លូវទឹក** : ការកសាងផ្លូវឆ្លងសមុទ្រទៅកាន់ទីក្រុងលង្ការបស់ក្រុមព្រះរាមដើម្បីជួយនាងសីតា។

### ៤.៣. តម្លៃលើផ្នែកសង្គមកិច្ច

- **សង្គមកិច្ច សុខាភិបាល៖** នៅមានលក្ខណៈបុរាណដោយប្រើថ្នាំជាឬសឈើ ស្លឹកឈើជាដើមព្យាបាលដូចដែលព្រះ លក្សណ៍។ ព្រះរាមបានបញ្ជាហនុមានឱ្យទៅលើកភ្នំ ដើម្បីរកថ្នាំព្យាបាល រហូតដល់ព្រះលក្សណ៍ជាសះស្បើយ។ ជាក់ស្តែងថ្នាំដែលត្រូវព្យាបាលព្រះលក្ស្មណ៍[11]មានបីមុខគឺ៖

| | | |
|---|---|---|
| *...«ពិភេកមើលយល់នូវជម្រា* | *ប្រើហនុមានជា* | *ដំនិតដំនឿព្រះចក្រី។* |
| *ឱ្យយកព្រះសង្ករណី* | *មួយយក**បុស្សទី**[12]* | *កេសរបទុមសោភា។* |
| *មួយយកនពតជាកមហា* | *ស្រះស្រង់វង់ថ្លា* | ***នូវម្ទូត្រឧសភរាជ**ថ្វាត[13]។...* |
| *...«ថ្នាំគ្រប់ដោយតំរាមាន* | *ក្រថ្មបស់ខាន* | *ពិភេកក៏ទូលបាទបទ។* |
| ***ថ្មជារឿងរ័តន៍មរកដ**[14]* | *កែវកើតកំណត់* | *សម្រាប់នៃថ្នាំនោះណា។»...* |

ប្រជាជនខ្មែរយើង បើទោះមកដល់សម័យវិទ្យាសាស្ត្ររីកចម្រើននេះក៏ដោយ ក៏ការប្រើប្រាស់ថ្នាំបុរាណនៅតែទទួលការពេញនិយមពីសំណាក់ប្រជាជនខ្មែរទូទៅ។ ទាំងនេះជាតម្លៃឆ្លុះបញ្ចាំងឱ្យឃើញពីឱសថបុរាណខ្មែរ គឺមានកំណើតតាំងតែពីយូរលង់អង្វែងឆ្នាំមកហើយ។

- **មុខរបរ និងជីវភាពរស់នៅប្រជាជន ៖** ហាក់បីដូចជាអ្នកនិពន្ធពុំបានបង្ហាញឱ្យមានភាពច្បាស់លាស់នៅឡើយទេ ថាប្រជាជនធ្វើការពិតប្រាកដ។ ប៉ុន្តែបើតាមរយៈបង្ហាញនៅក្នុងនគរមិថិលា ដែលព្រះចៅក្រុងមិថិលាធ្វើពិធីច្រត់ព្រះនង្គ័ល នេះបញ្ជាក់ថា ប្រជាជនប្រហែលជាប្រកបរបរកសិកម្ម ឬការដាំដុះដោយការ បេះផ្លែឈើ ដើម្បីទទួលទាន (កងទ័ពស្វា)។ ជាក់ស្តែងដូចក្នុងកំណាព្យថា[15]៖

---

[11] រឿងរាមកេរ្តិ៍ ខ្សែទី៩ ត្រង់ចន្លោះទំព័រទី១៧-២២, បោះពុម្ព ព.ស២៥៣៩ ដោយពុទ្ធសាសនបណ្ឌិត្យ

[12] ប្រហែលជា«បុស្ស៊ី» ដែលប្រែថា ផ្កា?

[13] ក្នុងច្បាប់សំស្ក្រឹតពោលចេញឈ្មោះថ្នាំគឺ ម្ឫតសញ្ជីវនី១ វិសល្យករណី១ សវណ៌ករណី១ សន្ធយានី១

[14] ឈ្មោះថ្នាំព្យាបាលព្រះលក្ស្មណ៍ ដែលមាននៅនគរលង្កា ស្ថិតនៅក្រោមកេសាខ្នើយក្រុងរាពណ៍។

[15] រឿងរាមកេរ្តិ៍ ខ្សែទី១ ត្រង់ទំព័រទី៥, បោះពុម្ព ព.ស២៥៣៩ ដោយពុទ្ធសាសនបណ្ឌិត្យ

*...«លុះពិសាខសុកតិត្ថី ផ្ទំមុខមន្ត្រី ប្រយោជន៍នូវប្រែពសុធា។*
*ដើម្បីនូវធ្វើឱ្យក្សេមដ៏ប្រជា រាស្ត្រផ្ទៃដោយនាក្រិតា ជិការដ៏បុរាណ។*
*ស្តេចទ្រង់នង្គ័លហសមាន ព្រះឧសុករាជបរិវារហាន ដំណើរសីហនាទលេលា។»....*
*..............................*
*...«[16]ខែដើមឆ្នាំហើយពុំយល់ អ្នកស្រែខ្វាយខ្វល់ នង្គ័លរនោសរាស់ក្ដួរ។*
*ក្រៀមក្រាំងរាំងរីងបឹងបួរ ស្រូវស្រែមានមួរ សឹងស្ងួតសឹងស្វិតស្លឹកស្លោម។»...*

- **ស្ថានភាពរស់នៅ** ៖ ហាក់បីពុំទាន់មានលក្ខណៈឯកភាពពីអ្នកនិពន្ធឡើយ ព្រោះពុំបានបង្ហាញឱ្យច្បាស់ទេ ពោលគឺមានតែការធ្វើសង្គ្រាមប៉ុណ្ណោះ។

### ៤.៤. តម្លៃលើផ្នែកវប្បធម៌

### ក. ជំនឿ

- **ការជឿទៅលើការទស្សន៍ទាយ**៖ ដែលមានពិភេកឱ្យគ្រូទាយយ៉ាងពូកែ ហើយអាចនិយាយជ័យជម្នះរបស់ព្រះរាមអាចកើតពីការទស្សន៍ទាយរបស់ពិភេកដូចជា៖ ខ្សែទី១០ទំ.១«*ពិភេកហោរឯកជែងជាញ ហោរសាស្ត្របង្ហាញ គឺទិព្វចក្ខុយង់យល់*។»... ក្រៅពីពិភេកនៅមានហោរាដូចជាជម្ពូពានទៀតផង។ ក្នុងក្បួនទាយដែលបន្តប្រើមកដល់សព្វថ្ងៃគឺមានប្រជុំក្បួនពិភេកហោរាជាដើម។
- **ជំនឿលើសត្វកុក**៖ ជឿទៅលើសត្វដែលមានសត្វកុកតំណាងឱ្យសត្វចង្រៃនាំមហន្តរាយ ឬភាពមិនល្អចំពោះស្រុកភូមិស្ថាន។ យ៉ាងនេះហើយបានជាព្រះលក្សណ៍ស្ទើរតែប្រហារសត្វកុកទៅហើយនៅពេលរិះគន់ទៅ លើព្រះរាមដែលមិនចេះថែរក្សាមហេសីឱ្យបានល្អ។ (រាមកេរ្តិ៍ខ្សែទី៤ ទំ.៣២)
- **ការជឿទៅលើអាទិទេព** ៖ ព្រោះថាមនុស្សគិតថាអាទិទេពជា អ្នកកំណត់អ្វីៗទាំងអស់ក្នុងលោក។
- **ជំនឿលើពិធីផ្សេងៗ**៖ ការធ្វើហោមពិធី ឬ ពិធីបូជាយញ្ញ ដើម្បីបង្ហាញពីកាគោរព និងឱ្យតម្លៃលើបុគ្គលណាម្នាក់ជាតំណាង។ ដូចដែលឥសីពិស្វាមិត្ររៀបចំហោមពិធី ដើម្បីបញ្ជាក់ថាព្រះរាមរៀនចេះចប់គម្ពីរត្រៃវេទ។ តម្លៃរឿងរាមកេរ្តិ៍នៅក្នុងកិច្ចពិធីខ្មែរ[17]គឺរឿងរាមកេរ្តិ៍ក្រៅពីការកត់ត្រាលើក្រាំងគម្ពីរនានាគេក៏យកឈុតផ្សេងៗនៃរឿងនេះមកលេងជាល្ខោនដែរ តែល្ខោននោះមានលក្ខណៈជាកិច្ចពិធីផង គឺថាពុំមែនគ្រាន់តែមើលកម្សាន្តប៉ុណ្ណោះឡើយ។ ក្រុមល្ខោនបានលេងរឿងរាមកេរ្តិ៍ ដោយប្រើផ្ទាំងស្បែកដើម្បីបង្ហាញតួអង្គព្រមទាំងសាច់រឿង ហើយដែលគេហៅថា «ស្បែកធំ» ឬ «ណាំងស្បែក»។ តួអង្គក្នុងរឿងរាមកេរ្តិ៍បានក្លាយជាអ្នកតាល្បីល្បាញមួយឈ្មោះ «អ្នកតាកំហែង» ដែលជារូបហនុមាន ដ្បិតតាំងពីសម័យកណ្ដាលមកគេតែងហៅហនុមានថា«កំហែង»។ រូបកំហែង-ហនុមាននេះតែងឃើញមានជាប់នឹងទូកប្រណាំងនៅតាមវត្តផ្សេងៗក្នុងតំបន់ដែលលើកមកនេះ ថែមទាំងមានឈ្មោះនៅជាប់លើនោះផង។ ឧទាហរណ៍មានឈ្មោះថា «កំហែង បរមី» ឬ «កំហែងកុមារមហាហង្សសែនជ័យ» ជាដើម។ ចំណុចសំខាន់ពិសេសមួយទៀតគឺតួអង្គរាពណ៍ដែលគេតែងហៅថា «ទសមុខ»។ ជាធម្មតាមនុស្សម្នាទូទៅតែងចាត់ក្រុងរាពណ៍ថាជាតួអង្គអាក្រក់ សូម្បីតែនៅសិលាចារឹកសម័យបុរាណក៏មានបង្ហាញថា

---

[16] រឿងរាមកេរ្តិ៍ ខ្សែទី២ ទំព័រទី២៨ បោះពុម្ព ព.ស២៥៣៩ ដោយពុទ្ធសាសនបណ្ឌិត្យ

[17] http://www.yosothor.org/publications/khmer-renaissance/chapter-two/rerng-ream-ke-ning-ettiphol-knong-phity.html

ដូច្នោះដែរ ដូចជាការប្រៀបធៀបក្សត្រមួយអង្គនៅប្រទេសចម្ប៉ាដែលមកវាយលុកប្រទេសកម្ពុជាទៅនឹងក្រុងរាពណ៍។ ប៉ុន្តែនៅតំបន់ដែលនិយាយសព្វថ្ងៃនេះ ក្នុងចំណោមតួអង្គរឿងរាមកេរ្តិ៍ទាំងមូល មានតែពីរទេដែលលេចមុខធ្លោដោយសារគេគោរព **គឺកំហែងនិងទសមុខ** មានន័យថាហនុមាននិងរាពណ៍ សូម្បីតែព្រះរាមដែលឱ្យឈ្មោះដល់រឿងនោះក៏មិនសំខាន់អ្វីប៉ុន្មានដែរ។កស្តុតាងនៅវត្តកៀនស្វាយក្រៅមានគេមកសង់អគារមួយដែលគេហៅថា «ប្រាសាទ» នៅទីកន្លែងរោងទសមុខចាស់ ហើយដាក់ឈ្មោះថា «**ប្រាសាទលោកតាទស្សបារមីមុខជប់**» ដែលមនុស្សតែងមកធ្វើបុណ្យបន់ស្រន់។ វត្តស្វាយអណ្តែតនៅត្រើយម្ខាងដែលនិយាយពីមុននោះវិញ កាលពីមុនបាក់ច្រាំងទន្លេ មានខ្ទមអ្នកតាមួយទៀតហៅថា «អ្នកតាទសមុខ»។ ទាំងអស់នេះសុទ្ធតែបញ្ជាក់ថាពីអតីតកាលខ្មែរនិយមរឿងរាមកេរ្តិ៍ជាពន្លឹកដោយយករឿងនេះបានផ្សារភ្ជាប់ជាមួយជីវភាពរស់នៅរបស់ប្រជាជនស្ទើរគ្រប់រូបភាព។

➢ **ប្រពៃណីទំនៀមទម្លាប់**

- **ពិធីច្រត់ព្រះនង្គ័ល៖** បង្ហាញតាមរយៈព្រះបាទជនកបានធ្វើពិធីច្រត់ព្រះនង្គ័លនៅស្ទឹងយមុនា (រឿងរាមកេរ្តិ៍ ខ្សែទី១ ទំ.៥)។
- **ការទុកដាក់កូនចៅឱ្យមានគូស្រករ៖** ជាភារកិច្ចឪពុកម្តាយ ដូចជាព្រះបាទជនកបានរៀបចំពិធីប្រឡងប្រជែងរកកូនប្រសាប្រុស ដោយការប្រឡងលើកធ្នូសិល្ប៍កៅទណ្ឌសហស្សថាម ដែលមានទម្ងន់ធ្ងន់ស្មើនឹងបុរសមួយពាន់នាក់ទើបលើករួច។ វិធីនេះជាវិធីស្វែងរកបុរសមានសមត្ថភាពដូចជាព្រះរាម ដែលសក្តិសមជាស្វាមីនាងសីតា។ (រឿងរាមកេរ្តិ៍ ខ្សែទី១ ទំ.៥-១២)។
- **ការរៀបអភិសេក ឬមង្គលការ៖** អាពាហ៍ពិពាហ៍ ព្រះរាម និងសីតាបានប្រព្រឹត្តទៅនៅនគរមិថិលាជានគរ ព្រះបាទជនក ឬគេហដ្ឋានខាងស្រី។ ព្រះបាទជនកក៏បានចាត់សេនាឱ្យយាងព្រះបាទទសរថបិតារបស់ព្រះរាមឱ្យមកយាងចូលរួមការរៀបអភិសេកនេះដែរ។(រាមកេរ្តិ៍ ខ្សែទី១ ទំ.១៤)។
- **បុណ្យសព៖** ការចូលកោដ្ឋ បញ្ឆោតនាងសីតា ក៏បានស្តែងឱ្យឃើញពីវត្តមាននៃកោដ្ឋ ព្រោះខ្មែរយើងនិយមប្រើកោដ្ឋ មានទំហំធំសម្រាប់ដាក់តម្កល់សពចំពោះមហាក្សត្រ ឬឥស្សរជននានា។ កោដ្ឋមួយទៀត មានទំហំតូចសម្រាប់ដាក់អដ្ឋិធាតុក្រោយពីបូជារួចមក។ ការប្រកាន់ពាក្យសត្យ ឬពាក្យ សម្បថ ខ្មែរយើងតែងអនុវត្តនិងប្រកាន់ជារៀងរហូតមក។ ដូចជានាងសីតាបានសច្ចាថាមិនវិលចូលនគរវិញ ដរាបណាព្រះរាមមិនទាន់សុគតព្រោះដោយការប្រច័ណ្ឌរបស់ព្រះរាមមកលើព្រះនាង។ រឿងរាមកេរ្តិ៍ ខ្សែទី៨០ ទំ.២៦...«លុះដល់កោដ្ឋកែវហើយណា ប្រាសប្រាណសោកាសុបសៅ...»។

➢ **យ័ន្តគាថា៖** ក្នុងយ័ន្តគាថា ការចាក់សាក់ ក្បួនទស្សន៍ទាយ និងក្បួនមើលជំងឺ សុទ្ធតែបានរងឥទ្ធិពលពីរឿងរាមកេរ្តិ៍។

➢ **ក្បាច់គុនបុរាណខ្មែរ៖** ក្នុងក្បាច់គុនមានឈ្មោះក្បាច់ព្រះរាមផ្លែងសរជាដើម។ លើសពីនេះក្នុងការប្រកួតប្រជាល់ គេនិយមថ្វាយបង្គំគ្រូតាមក្បាច់ផ្សេងៗ ដែលជាប់ពាក់ព័ន្ធនឹងសាសនាព្រាហ្មណ៍។

ក្បាច់ថ្វាយបង្គំគ្រូទាំង១៧[18]នោះ មានទម្រង់ និងអត្ថន័យដោយឡែកពីគ្នា ដោយភាគច្រើនគឺយកតាមកាយវិការបស់សត្វនាគ សត្វគ្រុឌ និងកាយវិការរបស់តួអង្គសំខាន់ៗដែលមានក្នុងរឿងរាមកេរ្តិ៍។ ក្បាច់ថ្វាយបង្គំគ្រូដែលត្រូវបានសហព័ន្ធប្រដាល់កំណត់យកចំនួន១៧នោះ កើតមានតាំងពីពេលណានោះទេ ប៉ុន្តែយោងតាមការស្រាវជ្រាវ គឺប្រហែលជាកើតមានក្នុងសម័យដែលកម្ពុជាមានជំនឿខ្លាំងលើព្រហ្មញ្ញសាសនាទើបក្បាច់ទាំងនេះភាគច្រើន យកតម្រាប់តាមអវតារទាំងនោះដែលជាតួអង្គសំខាន់ក្នុងសាសនាព្រាហ្ម។ ក្បាច់ទាំង១៧នោះរួមមាន៖ *ក្បាច់ព្រះរាមផ្លែងសរ ក្បាច់ហនុមានចងស្ពានយកនាងសិតា ក្បាច់រាហូចាប់ច័ន្ទ ក្បាច់គុនទន្សាយប្រលែងព្រះច័ន្ទ ក្បាច់គ្រុឌចក់នាគ ក្បាច់ព្រហ្មមុខ៤ ក្បាច់ក្រមុំចូលម្លប់(ក្រមុំតែងខ្លួន) ក្បាច់កសិករធ្វើស្រែ ក្បាច់នាគពាំកែវ ក្បាច់នាគលេងទឹក ក្បាច់ក្រុងពពណ៍សម្តែងឫទ្ធិ ក្បាច់ព្រះលក្ខណ៍ព័ទ្ធសីមា ក្បាច់រំលឹកគុនគ្រូ ក្បាច់ទូកីលេងស្នែង ក្បាច់ទូកីសម្តែងឫទ្ធិ ក្បាច់ឥន្ទ្រីសម្តែងឫទ្ធិ និងក្បាច់ហនុមានសម្តែងឫទ្ធិ*។

- **ឈ្មោះទូក**៖ ដូចជាឈ្មោះ «កំហែងបារមី កំហែងរាមា សរព្រះរាមមានរិទ្ធិ អាវាយរាបត្បូងឃ្មុំ...
- **មន្តអាគម**៖ ក្នុងមន្តអាគមយើងមានគំនូរព្រះលក្សណ៍ គូសការពារព័ទ្ធសីមាមិនឱ្យអំពើអាបធ្មប់ ចូលយាយីបាន។ ក្នុងពិធីរំដោះគ្រោះ គេឆ្លាក់រូបព្រះរាម រូបហនុមាន ដាក់ជាប់នឹងកន្ទោងផង។
- **ឈ្មោះរុក្ខជាតិ**៖ ដូចជា ដើមពុកព្រះរាម សុខព្រះរាម លំពែងព្រះរាម ដើមសេដា សម៉ពិភេក ម្នាស់ឥន្ទជិត ជាដើម»។ ក្រៅពីនេះមានដាក់ឈ្មោះទុក្ខវាលិ ឬប្រទាលពូកែៗទៅតាមឈ្មោះក្នុងរឿងរាមកេរ្តិ៍ ដូចជាប្រទាលលំពែងព្រះរាម សំណុំព្រះរាម ប្រទាលហនុមាន មហាជម្ពូជាដើម។
- **ល្បែងចត្រង្គ** : យើងយកសាច់រឿងរាមកេរ្តិ៍ ដាក់ឈ្មោះឱ្យល្បិចដើរកូនឈើត្រង់ខ្លះ ដូចជាព្រះរាមចូលកោដិបញ្ឆោតនាងសីតា ហនុមានចងថ្នល់ជាដើម[19]។
- **រូបហនុមាន** : គំនូររូបហនុមានជាគំនូរដ៏មានប្រជាប្រិយនៅក្នុងសង្គមខ្មែរ រហូតដល់ខ្មែរ យករូបនេះជានិមិត្តរូបនៃកងទ័ពជាតិទៅទៀត។
- **សំណង់និងចំណីអាហារ** : ក្នុងប្រមាណមិនដល់៥០ឆ្នាំកន្លងមកនេះខ្មែរបានយកពាក្យ សរព្រហ្មាស ដាក់ឈ្មោះឱ្យរោងភាពយន្តមួយនៅភ្នំពេញ ហើយសរព្រះរាម និងនាសាសីតាជាឈ្មោះ សាច់គោច្រន្ធច និងជ្រក់ទៅវិញ[20]។

### ខ. សាសនា

ប្រជាជនខ្មែរយើងបានគោរពប្រណិបត្តិសាសនាព្រាហ្មណ៍អស់ជាច្រើនសតវត្ស មុននឹងប្តូរមកគោរពសាសនាព្រះពុទ្ធ(និកាយហីនយាន)វិញនាសម័យក្រោយៗមកទៀត។ គេសង្កេតឃើញ កស្តុតាងជាច្រើនដែលស្តែងបញ្ជាក់អំពីជំនឿរបស់ប្រជាជនខ្មែរគ្រប់ស្រទាប់វណ្ណៈចំពោះ ព្រហ្មញ្ញសាសនា ដោយមានសេសសល់នូវសំណង់ប្រាសាទចម្លាក់នានាជាច្រើននៅ ស្ទើរពាសពេញផ្ទៃនៃព្រះរាជាណាចក្រកម្ពុជា ក៏ដូចជានៅតាមអតីតដែនដីកម្ពុជាផងដែរ។ ប៉ុន្តែនៅពេលដែលអ្នកអានពិនិត្យឱ្យច្បាស់លាស់បន្ថែមទៀតនោះរមែងពិនិត្យ

---

[18] លោក នួន ភិរម្យ អតីតកីឡាករល្បីឈ្មោះ និងជាម្ចាស់ក្លិបនួន ភារម្យ គុនខ្មែរ បានអះអាងថា យោងតាមសៀវភៅក្បួនប្រដាល់ក្បាច់គុនបុរាណខ្មែរដែលសហព័ន្ធប្រដាល់ចែកឱ្យលោកក្បួនថ្វាយបង្គំគ្រូនៅក្នុងពិភពប្រដាល់មានទាំងអស់១៧ក្បាច់។

[19] មីសែលត្រាណេ, សិក្សារឿងរាមកេរ្តិ៍, ១៩៩៥

[20] មីសែលត្រាណេ, សិក្សារឿងរាមកេរ្តិ៍, ១៩៩៥

ឃើញលក្ខណៈពិសេសមួយនៅក្នុងរឿងរាមកេរ្តិ៍ខ្មែរ គឺលក្ខណៈពុទ្ធនិយមដែលមានពាសពេញ រឿងទាំងផ្នែកទស្សនៈទាំងផ្នែកពាក្យពេចន៍ជាច្រើនក្នុងទ្រឹស្តីពុទ្ធសាសនា។

- **ព្រាហ្មណ៍សាសនា** ៖ ព្រោះរឿងនេះបង្ហាញពីចលនាអក្សរសិល្ប៍ព្រាហ្មណ៍និយមហើយបានចាត់ទុកព្រះរាម ជាអវតារទី៧របស់ព្រះវិស្ណុ ហើយជាសភាវៈល្អមានជ័យជម្នះលើសភាវៈអាក្រក់។
- **ព្រះពុទ្ធសាសនា** ៖ ទោះបីជារឿងរាមកេរ្តិ៍ស្ថិតនៅក្នុងចលនាអក្សរសិល្ប៍ព្រាហ្មណ៍និយមក៏ដោយ តែរឿងនេះអ្នកនិពន្ធ មានទំនោរទៅព្រះពុទ្ធសាសនាដែរ។ ដូចព្រះរាមបានតាំងខ្លួនព្រះអង្គជាព្រះចង្កូមកែវ និង មទ្រីជាកន្សែស្រារពេជ្ជ។ នៅពាសពេញផ្ទៃរឿងអ្នកនិពន្ធតែងទាញភ្ជាប់តួអង្គព្រះរាមថាជាតួអង្គពោធិសត្វជានិច្ច ។ ដូចនៅខ្សែទី១ ទំព័រ៤៨ ថា[21]៖

*...«ព្រះរាមរូបាកាយ គឺអង្គនារាយណ៍ បុណ្យបរិបូណ៌ ពូជពង្សពុទ្ធង្កូល ត្រកូលក្សត្រដ៏វរវង្ស។*
*រីព្រះរាមសូរិយោពង្ស ពុទ្ធតេនដ៏ឧត្តុង្គ ស្តេចចង់ត្រអាលយាត្រា។*

ចំណែកក្នុងខ្សែទី២ ទំព័រ១១-១២ ថា[22]៖

*....«នេះគួរនាដូចកម្មផល កុសលអកុសល អំពល់អំបើពីមុខ។*
*បង្កើតកាលកបនូវសុខ ហើយបង្កើតទុក្ខ ពុំដែលនូវចៀសចាកឡើយ។*
*លុះបាននិព្វានជាបង្ហើយ នោះនៃទើបស្បើយ រដោះលែងជរាមរណ៍។»...*

ត្រង់ចំណុចនេះ គួរកត់សម្គាល់ថា ចាប់ពីចុងសម័យអង្គររៀងមក ព្រះពុទ្ធសាសនា មហាយាន និងព្រហ្មញ្ញសាសនាចាប់ស្រុតចុះ គួរឱ្យកត់សម្គាល់ ហើយពុទ្ធសាសនាថេរវាទ ក៏ចាប់មានតួនាទី និងឥទ្ធិពលយ៉ាងធំធេងនៅសង្គមកម្ពុជា។

**គ. ការអប់រំ**

- **សិក្សាគម្ពីរវេទ**៖ ជាការសិក្សាបែបសាសនាព្រាហ្មណ៍ អប់រំឱ្យជឿជាក់លើអាទិទេពមានព្រះព្រហ្ម ព្រះវិស្ណុនិងព្រះឥសូរ ដោយយល់ថាអាទិទេពជាអ្នកកំណត់ជោគវាសនារបស់មនុស្ស។ (រឿងរាមកេរ្តិ៍ ខ្សែទី១ ទំ.២) បានបង្ហាញពីការសិក្សារបស់ព្រះរាមព្រះលក្ស្មណ៍ជាមួយឥសីពិស្វាមិត្រ។
- **ការអប់រំតាមបែបបុរាណ** ៖ ឱ្យមនុស្សគោរពពាក្យសត្យ ឱ្យតម្លៃលើប្បវេណី ឱ្យមានភាពកតញ្ញូចំពោះគ្រួសារ។ ក្នុងការគោរពពាក្យសត្យទីមួយនិយាយពីនាងកៃកេសីនិងព្រះបាទទសរថដែលបានសន្យានឹងគ្នា៖(ទំព័រ៣៦)*...«ថាបពិត្រនាថម៌សត្យមត់ កាលស្តេចចេញផ្គត់ សង្គ្រាមសំដែងចេស្តា។*

*ច្បាំងឈ្នះព្រះអាទិត្យសុរិយា ស្តេចបានប្តេជ្ញា ពាក្យសត្យនឹងអញខ្ញុំហោង។*
*ថានូវឱ្យរាជ្យព្រះកិរុតគ្រង សោយរាជសម្បត្តិស្នង ព្រះបាទសម្តេចរាជា។»...*

*(ទំព័រ៣៨) ...«ឱ្យរាជនេះព្រះកិរុតគ្រង រីព្រះរាមរាជបុត្រច្បង នូវអនុជលក្សា។*
*ឱ្យទៅនៅនាព្រៃអធ្វា បួសកាន់សីលជា ឬសីបានបួនដណ្តប់ឆ្នាំ។»...*

ចំណែកពាក្យសត្យទីពីរឆ្លុះបញ្ចាំងត្រង់នាងសីតានិយាយនឹងបុត្រថាទាល់តែព្រះរាមសុគតទើបនាងវិលចូលនគរ៖ ខ្សែទី៨០ ទំព័រទី៥៖ *...«ថាបើព្រះអង្គសុគត មែនពិតប្រាកដជាក់ហើយ*
*សីមម្តាយវិលទៅកូនអើយ បង្គំព្រះសពក្សត្រថ្លៃ»...។*

---

[21] រឿងរាមកេរ្តិ៍ ខ្សែទី១ ត្រង់ទំព័រទី៤៨, បោះពុម្ព ព.ស២៥៣៩ ដោយពុទ្ធសាសនបណ្ឌិត្យ

[22] រឿងរាមកេរ្តិ៍ ខ្សែទី២ ត្រង់ទំព័រទី១១-១២, បោះពុម្ព ព.ស២៥៣៩ ដោយពុទ្ធសាសនបណ្ឌិត្យ

ទាំងអស់នេះសុទ្ធតែស្របនឹងសុភាសិតខ្មែរដែលប្រកាន់យកពាក្យសម្ដីជាចម្បងដូចជា៖ ***មនុស្សគេយកសម្ដី ដំរីគេយកភ្លុក, សម្ដីជាឯក លេខជាទោ អក្សរជាត្រី, អណ្ដាតជាអាទិកន្លង បានសុខទុក្ខផងក៏ព្រោះអណ្ដាត, នោបបាក់យកនោបជួស សម្ដីហួសគ្មានអ្វីជួសទេ, សម្ដីសរជាតិ មារយាទសរពូជ***...ដែលសុទ្ធតែជាពាក្យឃ្លាអប់រំឱ្យចេះប្រកាន់ពាក្យពិតសច្ចៈ ព្រោះមនុស្សថ្លៃថ្នូរ ឬថោកទាបគឺផ្ដើមចេញពីពាក្យសម្ដីនេះឯង។

**ឃ. សិល្បៈ**

ស្ថិតក្នុងទម្រង់សិល្បៈខ្មែរទាំង៧ រឿងរាមកេរ្តិ៍បានជ្រៀតចូលស្ទើរឥតចន្លោះឡើយដូចជា៖

- **ស្ថាបត្យកម្ម៖** បង្ហាញពីការកសាងផ្លូវថ្នល់កាត់សមុទ្រទៅលង្កា និងការកសាងប្រាសាទនានាតាំងពីបុរាណមកគឺមានគោលបំណងដើម្បីគោរពបូជាដល់អាទិទេពក្នុងព្រហ្មញ្ញសាសនា។ ក្នុងបុព្វហេតុសាសនា ការប្រកាន់ជំនឿសាសនាខុសៗគ្នា បានធ្វើឱ្យព្រះរាជាខ្មែរពុំព្រមគោរពបូជាប្រាសាទដដែលៗទេ ហើយក៏បានចាត់ឱ្យគេស្ថាបនាប្រាសាទដទៃទៀត តាមបំណង និងជំនឿរបស់ព្រះអង្គ។
- **ចម្លាក់៖** បើគេសង្កេតទៅលើសិល្បៈចម្លាក់វិញ នោះគេនឹងឃើញមាននៅលើចម្លាក់ទោល ចម្លាក់តាមវត្ត តាមប្រាសាទ។ ចម្លាក់នៅតាមអង្គរវត្ត និងប្រាសាទដទៃទៀត សុទ្ធតែបានគូរពីរឿងរាមកេរ្តិ៍។ ក្រៅពីចម្លាក់តាមប្រាសាទនៅមានចម្លាក់ផ្សេងៗទៀតដូចជានៅវត្តក្ដុល ចម្លាក់លើកញ្ចក់ជាដើម។
- **គំនូរ៖** គំនូរលើស្បែក គំនូរទំនើប គំនូរផ្សាយ គំនូរលម្អ គំនូរលើចានសម្រាប់ធ្វើជាអំណោយ ឆ្លាក់លើស្ពាន់ ការត្បាញលើពិដាន លើហូល ជាដើម។ យើងមើលគំនូរនៅព្រះទីន័ងទេវាវិនិច្ឆ័យ ដែលគូរនៅឆ្នាំ១៩១៧ ក៏មានរឿងរាមកេរ្តិ៍។ គំនូរនៅជុំវិញព្រះមហាស្វេត្រឆ័ត្រ ក៏មានរឿងរាមកេរ្តិ៍ដែរ។
- **តន្ត្រី៖** តាមរយៈសាច់រឿងរាមកេរ្តិ៍ ក្នុងខ្សែនីមួយៗគឺមានបទចម្រៀងបទភ្លេងបុរាណដូចជា[23] ៖ បទក្រាវណេក, បទច្រំតែង, បទច្រះ, បទច្រះដុក, បទច្រះរាម, បទច្រះហើយច្រំតែង, បទជន្ទា,បទជើតបទជើតច្រំតែង, បទជើតឈិង, បទជើតស្ដេចចេញ, បទជើតហើយច្រះ, បទដំណាក, បទថាប្រៀនប្រាក្រាប, បទថាពែនហើយពាតដែក, បណាគូ, បទបិនណាកឱត, បទបំរើ, បទបំរើសំណា, បទបំរើហើយសំរាង, បទប្រគំ, បទពាក់ដែក, បទព្រះលក្សណ៍វាន់មាលា, បទល្បងកាន់រួចជំហានធំ, បទសម្ដេច, បទសម្ដេចភាណ, បទសម្ដេចលា, បទសម្ដេចលេលា, បទសំការ, បទសំណា, បទសំណាខម, បទសំណាខរ, បទសំណាខ្មែរ, បទសំណាមន, បទសំណាលាវ, បទសំណាសៀម, បទសំណាសៀមសុទ្ធ, បទសំណាស្ដេចលេលា, បទសំរើប, បទឱត, បទឱតសៀម។
- **របាំ៖** របាំមហោស្រពសុទ្ធតែមានរឿងរាមកេរ្តិ៍។ ការសម្ដែងរបាំមានដូចជា៖ របាំរឿងរាមកេរ្តិ៍ទម្រង់១០០ឆ្នាំ ដែលផលិតដោយព្រះរៀបនរោត្តមបុប្ផាទេវី នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៩[24]។
- **អក្សរសិល្ប៍៖** មានជាស្នាដៃរឿងរាមកេរ្តិ៍សម្រាប់សិក្សា ដែលក្រសួងអប់រំដាក់ជាកម្មវិធីសម្រាប់មធ្យមសិក្សាទុតិយភូមិ។ មិនតែប៉ុណ្ណោះ ខ្មែរបានយករឿងរាមកេរ្តិ៍នេះទៅសម្ដែងសិល្បៈដូចជា ល្ខោនក្បាច់បុរាណខ្មែរ(សព្វថ្ងៃហៅល្ខោនព្រះរាជទ្រព្យ ល្ខោនហ្លួង) ល្ខោនខោល ល្ខោនស្បែកធំ គំនូរនៅតាមជញ្ជាំងព្រះវិហារផ្នែកពុទ្ធសាសនា ការនិទានរឿងជូនសាធារណជនកម្សាន្ត ការសម្ដែងភាពយន្តជាដើម។ បានសេចក្ដីថា រាមកេរ្តិ៍បានជះឥទ្ធិពលយ៉ាងខ្លាំងលើខ្មែរគ្រប់រូប គ្រប់សម័យកាលរហូតដល់

---

[23] ឡុច ផ្លេង, ប្រជុំវប្បធម៌ទូទៅ ,បោះពុម្ពដោយៈ វិទ្យាស្ថានជាតិខេមរយានកម្ម,ភ្នំពេញៈ ១៩៧៣

[24] https://youtu.be/L2ETIlFzcOI

បច្ចុប្បន្ននេះ។ ក្នុងប្រពៃណីខ្មែរបុរាណនៅពេលកើតទុរ្ភិក្សអត់បាយអ្នកស្រុកតែងតែយករឿងរាមកេរ្តិ៍ទៅសម្តែងជា សិល្បៈល្ខោនចំនួន**៧យប់៧ថ្ងៃ** ទាល់តែមានភ្លៀងធ្លាក់តែម្តង[25]។ ឈុតខ្លះនៃរឿងរាមកេរ្តិ៍ត្រូវបានយកទៅសម្តែងជាល្ខោនដូចជាឈុត៖ ហនុមានរំដោះព្រះរាម, ហនុមានថ្វាយព្រះទម្រង់, ឈុតព្រះរាមព្រះលក្ស្មណ៍ សីតាដើរទេស...។

- **ភាពយន្ត៖** សាច់រឿងរាមកេរ្តិ៍ត្រូវបានគេយកមកសម្តែងជាភាពយន្តដាក់បញ្ចាំងតាមប្រព័ន្ធផ្សព្វផ្សាយផ្សេងៗ ទុកជាការកម្សាន្ត និងចំណេះដឹង។

ក្រៅពីទម្រង់សិល្បៈទាំង៧នេះ រឿងរាមកេរ្តិ៍បានបង្ហាញលើតម្បាញខ្មែរ ត្បាញជារូបហូលពិតាន ធ្វើជាមុខខ្នុក ចម្លាក់ជាបដិមាទោល សម្តែងជាល្ខោនខោល ល្ខោនស្បែកធំ និទានផ្ទាល់មាត់។ល។

**ឃ. ភាសា-អក្សរ**

តាមរយៈសាសនាព្រាហ្មណ៍ ខ្មែរបានទទួលនូវការប្រើប្រាស់ភាសាបាលីសំស្រ្កឹត ដែលរហូតមកដល់បច្ចុប្បន្នយើងនៅតែបន្តប្រើមិនទាន់ឈប់នៅឡើយទេ។

តួអក្សរខ្មែរត្រូវបានគេយកទៅធៀបនឹងរូបតួអង្គរឿងរាមកេរ្តិ៍។ ខាងក្រោមនេះគឺគំនូរតួអង្គនៃរឿងរាមកេរ្តិ៍ គូរនៅឆ្នាំ១៩៣៤ ដោយជាង **តឹក ជាង**ព្រះរាជបណ្ណាល័យ និងចំណាងជើងដោយព្រះមហាពិទូរក្រសេម[26]



**៤.៥. តម្លៃតាមរយៈលក្ខណៈអក្សរសិល្ប៍**

រឿងរាមកេរ្តិ៍បានឆ្លុះបញ្ចាំងនៅស្ទើរគ្រប់លក្ខណៈនៃអក្សរសិល្ប៍គឺ៖

- **លក្ខណៈមនុស្ស៖** លក្ខណៈមនុស្សក្នុងអក្សរសិល្ប៍ គឺលើកយកបញ្ហាមនុស្សមកចោទ និងដោះស្រាយទៅតាមសកម្មភាពធម្មតារបស់មនុស្សដោយបង្កើតជាបញ្ហានៅក្នុងរឿងហៅថា«បញ្ហាមនុស្ស» ។ អ្នកនិពន្ធខ្មែរបានលើកតម្កើងព្រះរាម ហើយផ្នែកខ្លះទៀតបញ្ចុះតម្លៃបន្តិចម្តងៗ រហូតក្លាយជា មនុស្សភាព ឬអន់ជាងមនុស្សសាមញ្ញទៀតផង ដូចជាព្រឹត្តិការណ៍យំសោកពេលបាត់សីតា ដេរសត្វកុក បាត់ម្ចាស់ការ លួចសម្លាប់ពាលី សម្លុតគំរាម ល្បិចកិច្ចកលនានា ដែលសុទ្ធតែជាលក្ខណៈរបស់មនុស្សក្នុងលោក។ តួអង្គក្នុងរឿងដែលមានយក្ស ស្វា ត្រី ក្របី ...សុទ្ធតែតំណាងឱ្យមនុស្សក្នុងសង្គមទាំងអស់។
- **លក្ខណៈសង្គម៖** គឺលើកយកបញ្ហាមនុស្សក្នុងសង្គមណាមួយមកចោទ និងដោះស្រាយតាមសភាពលក្ខណៈរបស់ខ្លួន ទោះបីចម្រើនក្តី ធម្មតាក្តី ឬអន់ថយក្តី។ តួអង្គនីមួយៗគឺមិនតំណាងតែមតិយោបល់ និងសកម្មភាពនៅក្នុងរឿងទេ តែត្រូវតំណាងសង្គមារម្មណ៍ ឬមនុស្សភាគច្រើន ។ ហេតុដូច្នេះហើយបានជាគេពោលថា «*អក្សរសិល្ប៍ជាកញ្ចក់សម្រាប់ឆ្លុះបញ្ចាំងនូវតថភាពសង្គម*» ។ តាមរយៈសាច់រឿង

---

[25] មីសែលត្រាណេ, សិក្សារឿងរាមកេរ្តិ៍, ១៩៩៥

[26] សាគូ សាមុត, រឿងរាមកេរ្តិ៍ ទំព័រ២១១ បោះពុម្ពឆ្នាំ២០០៧ ដោយបណ្ណាគារអង្គរធំ

រាមកេរ្តិ៍បានឆ្លុះបញ្ចាំងពីសង្គមប្រកបដោយសង្គ្រាម ការកាប់សម្លាប់ដើម្បីអំណាច ការលួចក្បត់ចុះចូលខ្មាំងសត្រូវ ការសេងសឹក ការប្រើវិធីសាស្ត្របញ្ចុះបញ្ចូល ភាពលោភលន់ ដែលសុទ្ធជាបញ្ហាក្នុងសង្គម។

- **លក្ខណៈវណ្ណៈ៖** អក្សរសិល្ប៍ គឺជាការឆ្លុះបញ្ចាំងនូវរូបភាពមនសិការសង្គម ដូច្នេះអក្សរសិល្ប៍ត្រូវតែឆ្លុះបញ្ចាំងនូវមូលដ្ឋានជាក់ស្តែងមួយជាដាច់ខាត។ ចរិតលក្ខណៈនេះ បានស្តែងឡើងតាមរបៀបរស់នៅ ទឹកចិត្ត ស្មារតី សញ្ចេតនា ផលប្រយោជន៍សេដ្ឋកិច្ចរបស់មនុស្ស ដែលស្ថិតក្នុងស្រទាប់វណ្ណៈ សង្គមខុសគ្នា ។ ការនិពន្ធរឿងរាមកេរ្តិ៍បានបង្ហាញឱ្យឃើញទំនាស់រវាងវណ្ណៈនេះ គឺជាការចោទបញ្ហាមិនចេះចប់រវាងអ្នកបួសនិងពពួកយក្សអសុរៈ។
- **លក្ខណៈប្រជាជន៖** គឺនិយាយយ៉ាងច្រើនពីផ្នត់គំនិត សតិអារម្មណ៍ ព្រលឹងចំណង់ចំណូលចិត្តរបស់ប្រជាជន ហើយជាងនេះទៅទៀតបានចេញមុខការពារនូវផលប្រយោជន៍ប្រជាជន ប្រឆាំងនឹងអំពើកេងប្រវ័ញ្ចសព្វបែបយ៉ាងនៃក្រុមឱកាសនិយម និងវណ្ណៈជិះជាន់ ។ ក្នុងរឿងរាមកេរ្តិ៍ បង្ហាញពីផ្នត់គំនិតប្រជាជនក្នុងការប្រកាន់យកពាក្យ**សត្យ** ដែលតាមរយៈនេះព្រះរាមបានចេញមុខដោះស្រាយទំនាស់ដើម្បីការពារសន្តិភាពក្នុងនគរ ជៀសវាងសង្គ្រាមដណ្តើមរាជ្យដែលនាំឱ្យមានបញ្ហាទាំងរាជវង្ស និងប្រជានុរាស្ត្រ។ នេះជាការបង្ហាញពីមនោសញ្ចេតនា ឧត្តមគតិ និងសុច្ឆន្ទៈ ដើម្បីបម្រើនូវសេចក្តីត្រូវការក្នុងជីវភាពប្រជាជននិងមានអត្ថន័យសង្គមយ៉ាងធំធេងប្រកបដោយលក្ខណៈប្រជាធិបតេយ្យ[27] ។
- **លក្ខណៈប្រវត្តិ៖** ជាស្នាដៃអក្សរសិល្ប៍ទាក់ទងទៅនឹងសម័យកាល ឬព្រឹត្តិការណ៍ខ្លះៗដែល កើតមានឡើងនៅក្នុងប្រវត្តិសាស្ត្រ[28] ។ រឿងរាមកេរ្តិ៍បានផ្សារភ្ជាប់សាច់រឿងទៅគ្រប់សម័យកាល[29]
    - សម័យបុរាណ (ស.វទី៦-១៤) គឺមានរូបចម្លាក់តួអង្គព្រះរាមតាំងពីស.វ.ទី៦ឬទី៧ នៅខេត្តតាកែវ មានសិលាចារឹកវាលកន្ទេល K.359 ស.វ.ទី៧ និយាយពីគម្ពីររឿងរាមកេរ្តិ៍ មានចម្លាក់រឿងរាមកេរ្តិ៍តាមប្រាសាទរាប់មិនអស់នៅសម័យអង្គរ និងមានឈ្មោះតួអង្គរឿងរាមកេរ្តិ៍ក្នុងសិលាចារឹកច្រើននៅសម័យអង្គរ។
    - សម័យកណ្តាល(ស.វ.ទី១៥-១៩) រឿងរាមកេរ្តិ៍ខ្មែរ ដែលជាអត្ថបទសរសេរនៅគង់វង្សគឺមានស្នាដៃ(ច្បាប់)ផ្សេងៗដែលចារចម្លងតៗគ្នាលើសាស្ត្រាស្លឹករឹតតាំងពីស.វ.ទី១៦-១៧។
    - រឿងរាមកេរ្តិ៍ខ្មែរសម័យថ្មី(ស.វ.ទី១៩-បច្ចុប្បន្ន) មានអត្ថបទច្រើនស្នាដៃ(ច្បាប់)ផ្សេងៗគ្នា និងមានអ្នកចេះនិទានតាមតំបន់ផ្សេងៗ មានគួរជាគំនូរ ឬចម្លាក់នៅតាមវត្តអារាមនានា និងមានការនិយាយខ្លីៗនៅក្នុងក្បួនទាយ ឬក្បួនមើលជំងឺផ្សេងៗ។

ក្រៅពីនេះមានចម្លាក់រឿងរាមកេរ្តិ៍[30]មានតាំងពីសម័យសម្បូរណ៍ព្រៃគុក(ស.វ.ទី៧) ខ្សែរូបនីយកម្មផ្នែកសិល្បៈបង្ហាញកាន់តែច្បាស់នៅចុង ស.វ.ទី១០(ក្បាច់នៅជញ្ជាំង និងស៊ុមទ្វារប្រាសាទបន្ទាយស្រី) នៅប្រាសាទបាពួន(ដើម ស.វ.ទី១១) នៅជញ្ជាំងអង្គរវត្ត បាយ័ន និងបន្ទាយសំរែ(ស.វ.ទី១២)។

[27] ក្រសួងអប់រំ, អក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២ ទំព័រ ៥៨, ២០១៦
[28] ក្រសួងអប់រំ, អក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២ ទំព័រ ៥៨, ២០១៦
[29] ព្រាប ចាន់ម៉ារ៉ា រឿងរាមកេរ្តិ៍ ក្នុងជំនឿទំនៀមទម្លាប់សិល្បៈនិងសង្គមខ្មែរ ២០១៦
[30] សាគូ សាមុត, រឿងរាមកេរ្តិ៍, បោះពុម្ពដោយបណ្ណាគារអង្គរ ២០០៧

- **លក្ខណៈជាតិ៖** ស្នាដៃដែលអ្នកនិពន្ធបានបំផុសបង្ហាញយ៉ាងណាឱ្យឃើញទំនៀមទម្លាប់ ប្រពៃណីល្អរបស់ជាតិ រួចការពារដួងព្រលឹង និងនិមិត្តរូបរបស់ជាតិឱ្យស្ថិតស្ថេរគង់វង្ស និងចេះច្នៃឥទ្ធិពល បរទេសឱ្យស្របនិងវប្បធម៌ជាតិ ។ លក្ខណៈជាតិក៏តម្រូវឱ្យមានការទទួលយកវប្បធម៌ បរទេសជឿនលឿនមកបំពេញបន្ថែមលើវប្បធម៌ជាតិខ្លួនឱ្យកាន់តែមានភាពប្រសើរឡើងដែរ ប៉ុន្តែត្រូវស្ថិតក្នុងលក្ខខណ្ឌរក្សាលក្ខណៈជាតិជានិច្ច។ ស្នាដៃរឿងរាមកេរ្តិ៍ថ្វីបើមានការលើកឡើងថាចម្លងពីរឿងរាមាយណៈឥណ្ឌាពិតមែន តែដំណើររឿងបានឆ្លុះបញ្ចាំងពីលក្ខណៈជាតិជាច្រើនដូចជា៖ ការជ្រើសរើសកូនប្រសារ(លើកធ្នូកៅទណ្ឌសហស្សថាម), ការរៀបអាពាហ៍ពិពាហ៍(នៅនគរខាងស្រីគឺមិថិលា), ការធ្វើពិធីច្រត់ព្រះនង្គ័ល(ព្រះបាទជនក), ភក្តីភាពរបស់នារីខ្មែរ(សីតាស្មោះនឹងព្រះរាម)។ល។
- **លក្ខណៈអន្តរជាតិ៖** ជាស្នាដៃ ដែលបម្រើនូវឧត្តមគតិ និងផលប្រយោជន៍របស់មនុស្សជាតិទូទៅ មានតម្លៃគ្រប់សម័យកាល មានខ្លឹមសារបម្រើផលប្រយោជន៍សង្គមសមូហភាពអន្តរជាតិ។ លើសពីនេះជាស្នាដៃដែលបានបណ្តុះនូវផ្នត់គំនិតសីលធម៌ជឿនលឿន សិក្សាស៊ីជម្រៅលើផ្នែកសង្គមសាស្ត្រ មនោគមវិជ្ជានយោបាយ។ ជាពិសេសវាបានជះឥទ្ធិពលទាំងផ្នែកអត្ថន័យ និងផ្នែកអត្ថរូបទៅលើឆាកអន្តរជាតិទទួលយកមកសិក្សាដូចស្នាដៃជាតិរបស់ខ្លួនដែរ។ ដោយសាររឿងរាមកេរ្តិ៍មានទំនាក់ទំនងនឹងរឿងរាមាយណៈឥណ្ឌា ដូច្នេះរឿងនេះបានបង្ហាញពីការជះឥទ្ធិពលទៅលើប្រទេសនានាដែលជាលក្ខណៈអន្តរជាតិនៃរឿង។ ជាក់ស្តែងតាមរយៈនៃការសិក្សាកន្លងមក រឿងរាមាយណៈផ្សាយឥទ្ធិពលដូចជា៖ ឥណ្ឌា(រាមាយណៈ), ខ្មែរ(រាមកេរ្តិ៍), ថៃ(រាមាគៀនRamakien),ភូមា(Yamayana), ម៉ាឡេស៊ី(Hikayat Seri Rama), ឥណ្ឌូណេស៊ី(KakawinRāmāyana'), ហ្វីលីពីន(Maharadia Lawana), ឡាវ(Phra Lak Phra Lam), ជប៉ុន (Hobutsushu), នេប៉ាល់(Siddhi Ramayan), ស្រីលង្កា(Janakiharan), អ៊ីរ៉ង់(Dastan-e-Ram O Sita), ចាម្ប៉ា(ព្រហ្មទិត្យ ព្រហ្មលក្ខ)។

ការហូរឥទ្ធិពលទៅបណ្តាប្រទេសនានានេះហើយដែលឆ្លុះឱ្យឃើញថា ប្រទេសផ្សេងដទៃទៀតដែលនៅក្បែរប្រទេសខ្មែរ ក៏អាចទាញយកអក្សរសិល្ប៍រឿងរាមកេរ្តិ៍ចេញពីប្រទេសខ្មែរ យកទៅសិក្សានៅប្រទេសរបស់ខ្លួនដែរ ព្រោះអាណាចក្រខ្មែរក៏មានកំណើតក្នុងកាលដ៏យូរលង់មុនប្រទេសនានានៅអាស៊ីអាគ្នេយ៍។

ចំណុចសំខាន់មួយទៀតនៃលក្ខណៈអន្តរជាតិ គឺរឿងរាមកេរ្តិ៍ ដែលនិទានដោយតាគ្រុឌជាផ្នែកមួយនៃបេតិកភណ្ឌសោតទស្សន៍ខ្មែរ និងត្រូវបានដាក់បញ្ចូលទៅក្នុងបញ្ជីនៃការចងចាំរបស់ពិភពលោករបស់អង្គការយូណេស្កូ នៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៤[31]។

### ៤.៦. តម្លៃតាមរយៈចលនាអក្សរសិល្ប៍

ដូចបានដឹងស្រាប់មកហើយថា ចលនាអក្សរសិល្ប៍ត្រូវបានបែងចែកជា៤ចលនាគឺ៖ ចលនាពុទ្ធនិយម ចលនាព្រាហ្មណ៍និយម ចលនាខេមរនិយម និងចលនាបរទេសនិយម។

តាមរយៈដំណើររឿងរាមកេរ្តិ៍បានឱ្យឃើញថា ពេលខ្លះ ព្រះរាមមានសមត្ថភាពអស្ចារ្យ គឺខ្លាំងក្លាហួសពីមនុស្សធម្មតា។ ដូចជានៅពេលផ្តើមរឿងកវីបានបង្ហាញពិធីបូជាយញ្ញតាមព្រហ្មញ្ញ សាសនា គឺហោមពិធីរបស់

[31] https://bophana.org/km/events/

ឥសីពិស្វាមិត្រ។ តាមរយៈភស្តុតាងខាងលើនេះ គេអាចសន្និដ្ឋានថា រឿងរាមកេរ្តិ៍ គឺជារឿងដែលស្ថិតនៅក្នុង **ចលនាព្រាហ្មណ៍និយម**។

ប៉ុន្តែពេលខ្លះទៀតព្រះរាមបែរ ជាមានលក្ខណៈ ជាមនុស្សទៅវិញ គឺដោះស្រាយបញ្ហាគ្រប់យ៉ាង ដូចជាមនុស្សធម្មតា ដែលចេះគំរាមកំហែងកុហក បោកប្រាស់ប្រច័ណ្ឌជាដើម។ តាមហេតុផលនេះ អាចនិយាយថា រឿងរាមកេរ្តិ៍មានដំណោះស្រាយតាមបែបមនុស្សសាមញ្ញ ដែលមានទំនោរទៅរកមនុស្សនិយម។ ទន្ទឹមនឹងនេះ ក្នុងស្នាដៃខាងលើ គេសង្កេតឃើញថាបើព្រះរាមមានសកម្មភាពដ៏ ត្រឹមត្រូវ នេះកវីហៅព្រះរាមតាមពុទ្ធសាសនាថា«ពុទ្ធង្កុរ»គឺសំដៅព្រះរាម(ខ្សែ១ទំព័រទី ៤៨) កន្សែងសារពេជ្ជ គឺសំដៅនាងសីតា(ខ្សែ២ទំព័រទី៤)។ ពេលខ្លះទៀត មានលើកយកបញ្ហាកម្មផលក្នុងទ្រឹស្តីពុទ្ធនិយមមកបង្ហាញដែរ។ ជាក់ស្តែងពេលនាងសីតាព្រាត់ពីព្រះរាម កវីប្រើពាក្យកម្មពៀរវេរា។ ដូច្នេះគេអាចសន្និដ្ឋានបានថា កវីនិពន្ធរឿងរាមកេរ្តិ៍ទទួលឥទ្ធិពល ពីព្រះពុទ្ធសាសនាយ៉ាងច្រើន។

លើសពីលាយបញ្ចូលនូវទ្រឹស្តីពុទ្ធនិយម រឿងរាមកេរ្តិ៍ក៏បានផ្សារភ្ជាប់នូវខេមរនិយមផងដែរ តាមរយៈរបៀបរបបនៃការរស់នៅ លក្ខណៈសាមញ្ញមានស្នេហា ប្រច័ណ្ឌច្រណែនឈ្នានីស សងសឹកមិនចប់មិនហើយ ជាពិសេសទៅទៀតនោះគឺការប្រកាន់ភ្ជាប់នូវពាក្យសច្ចៈដែលជាផ្នត់គំនិតដ៏ល្អរបស់ខ្មែរយើង។

ជារួមមកវិញស្នាដៃអក្សរសិល្ប៍រាមកេរ្តិ៍ដែលស្ថិតក្នុងចលនាអក្សរសិល្ប៍ព្រាហ្មណ៍និយមក៏ពិតមែន តែហាក់ដូចជាមានផ្សារភ្ជាប់នូវទ្រឹស្តីពុទ្ធនិយម និងខេមរៈនិយម ដែលជាហេតុយ៉ាងច្បាស់នាំឱ្យយើងទាញបានថា រឿងរាមកេរ្តិ៍ឆ្លុះបញ្ចាំងនូវខេមរនីយកម្ម ជាលក្ខណៈរបស់ជាតិខ្មែរ។

**៥. សន្និដ្ឋាន**

ដូច្នេះយើងឃើញថា រឿងរាមកេរ្តិ៍មានឥទ្ធិពលយ៉ាងទូលំទូលាយលើគ្រប់មជ្ឈដ្ឋានតាំងពីជំនឿកំប៉ិកកំប៉ុក តាំងតែពីរូបភាពផ្សេងៗនៃគំនូរចម្លាក់ រហូតដល់គំនិតខាងសោភ័ណវិជ្ជា ជំនឿសាសនា និងទស្សនវិជ្ជា ទំនៀមទម្លាប់ប្រពៃណីរបស់ប្រជាពលរដ្ឋ និងលើផ្នែកប្រវត្តិសាស្ត្រនៃអារ្យធម៌ខ្មែរ។ តម្លៃនៃអក្សរសិល្ប៍រឿងរាមកេរ្តិ៍ គឺបានដក់ជានក្នុងសន្តានចិត្តប្រជាជនខ្មែរតាំងពីដើមរហូតរៀងមក។ អ្នកនិពន្ធមានសិល្បវិធី ក្នុងការតែងនិពន្ធបានល្អមិនអាចកាត់ថ្លៃបាន។ តម្លៃរឿងរាមកេរ្តិ៍ខ្មែរ បានឆ្លុះបញ្ចាំងនូវខេមរនីយកម្មលើគ្រប់ផ្នែកដូចជាផ្នែកនយោបាយ ផ្នែកសេដ្ឋកិច្ច ផ្នែកសង្គមកិច្ច ផ្នែកវប្បធម៌ ឆ្លុះបញ្ចាំងនូវលក្ខណៈមនុស្សនិយមតាមរយៈ ជំនឿសាសនា ការអប់រំ សិល្បៈ ភាសាអក្សរជាដើម។ លើសពីនេះស្តែងឡើងតាមរយៈផ្នែកសំខាន់ៗរបស់ជាតិ រឿងរាមកេរ្តិ៍ហាក់បានក្តោបនូវស្ទើរគ្រប់លក្ខណៈ និងចលនាអក្សរសិល្ប៍ ដែលបង្ហាញពីអំណាចឥទ្ធិពលនៃអក្សរសិល្ប៍។ អ្នកនិពន្ធរឿងរាមកេរ្តិ៍ខ្មែរបានយកចិត្តទុកដាក់ជាខ្លាំងលើលោកិយសច្ចៈជាអាទិភាព ដែលចំណុចនេះគឺខុសប្លែកពីរឿងដើមរបស់ឥណ្ឌា គឺបានឱ្យតម្លៃទៅ លើអច្ឆរិយភាពជាធំ។ មិនតែប៉ុណ្ណោះ កវីនិពន្ធយើងក៏បានបញ្ចូលនូវទស្សនៈពុទ្ធនិយម ដើម្បីកំណត់ខ្លឹមសារស្នាដៃឱ្យកាន់តែសុក្រិត្យស្របតាមទស្សនៈមនុស្សខ្មែរនាសម័យកាលនោះ ដែលកំពុងតែមានទំនោរទៅរកសាសនាព្រះពុទ្ធ។

ឆ្លងតាមសេចក្តីអធិប្បាយមកទាំងប៉ុន្មានខាងលើនេះ គឺពិតជាមិនទាន់មានខ្លឹមសារពេញលេញគ្រប់ជ្រុងជ្រោយនៅឡើយទេ។ តែយ៉ាងណាការសិក្សានេះអាចបានជាគន្លឹះ ជាចំណេះដឹងខ្លះៗក្នុងការឆ្លុះបញ្ចាំងពីតម្លៃនៃរឿងរាមកេរ្តិ៍ក្នុងវប្បធម៌ជាតិ។ ការសិក្សានេះជាការរួមចំណែកក្នុងវិស័យអំណាន ដើម្បី**បណ្តុះបញ្ញា ការស្រាវជ្រាវ និងធ្វើនូវនវានុវត្តន៍** ក្នុងន័យពង្រឹងនិងពង្រីកចំណេះដឹងក្នុងការជួយសង្គមជាតិឱ្យអភិវឌ្ឍ។

# ឯកសារពិគ្រោះ

១.ឃីង ហុកឌី, ទិដ្ឋភាពទូទៅនៃអក្សរសាស្ត្រខ្មែរ, បណ្ណាគារអង្គរ, ២០០៣ ។
២. ពុទ្ធសាសនបណ្ឌិត្យ, រាមកេរ្តិ៍, ខ្សែ១ ដល់១០ និង៧៥ ដល់៨០, បោះពុម្ពលើកទី៣,១៩៥៩ ។
៣. លាង ហាប់អាន, សិក្សាអត្ថបទរឿងរាមកេរ្តិ៍, ខ្សែ៧៥ដល់៨០, ១៩៦៧ ។
៤. សាគូ សាមុត, រឿងរាមកេរ្តិ៍ បណ្ណាគារ អង្គរ, ២០០៧ ។
៥. ព្រាប ចាន់ម៉ារ៉ា, រឿងរាមកេរ្តិ៍ ក្នុងជំនឿទំនៀមទម្លាប់សិល្បៈនិងសង្គមខ្មែរ ២០១៦។
៦. ឡុច ផ្លេង, ប្រជុំវប្បធម៌ទូទៅ ,បោះពុម្ពដោយៈ វិទ្យាស្ថានជាតិខេមរយានកម្ម,ភ្នំពេញៈ ១៩៧៣។
៧. មីសែលត្រាណេ, សិក្សារឿងរាមកេរ្តិ៍, ១៩៩៥។
៨. នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា, សិក្សាអត្ថបទអក្សរសិល្ប៍, ឆ្នាំ២០១៩។
៩. សម្តេចព្រះសង្ឃរាជ ជួន ណាត, វចនានុក្រមខ្មែរ ១៩៦៧។
១០. វ៉ា សារឿន, រាមកេរ្តិ៍ ១៩៩៣។
១១. លាង ហាប់អាន, រឿងរាមកេរ្តិ៍, រាមកេរ្តិ៍បែបខ្មែរ, រាមាយណៈបែបឥណ្ឌា ។
១២. អ៊ីវ ចុង, អក្សរសិល្ប៍ខ្មែរ ២០១៣។
១៣. សរ សារុន, សង្ខេបរឿងរាមកេរ្តិ៍, (គ្មានកាលបរិច្ឆេទ) ។
១៤. ពៅ សាមី, មូលដ្ឋានទ្រឹស្តីអក្សរសិល្ប៍,១៩៨៧។
១៥. អ៊ីវ ចុង, សាកល្បងសិក្សារឿងរាមកេរ្តិ៍ , ២០១៨